ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឯកសារបណ្តុះបណ្តាល

ស្តីអំពី

# ការចុះបញ្ជីគណនេយ្យ
# សម្រាប់សហគមន៍កសិកម្ម

ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម

នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង

ខែ ឧសភា ឆ្នាំ ២០១៨

# មាតិកា


មេរៀនទី១ អ្វីទៅជាការចុះបញ្ជីគណនេយ្យ ?......1
១ និយមន័យ......1
២ គោលបំណងនៃការចុះបញ្ជីគណនេយ្យ......1
៣ ប្រភេទគណនេយ្យទាំង ២ប្រភេទ......2
៣១. គណនេយ្យឯកភាគ......2
៣២. គណនេយ្យទ្វេរភាគ......2
មេរៀនទី២ ប្រតិបត្តិការ និង គណនី......5
១ ប្រតិបត្តិការ......5
២ គណនី......5
មេរៀនទី៣ ទ្រព្យសកម្ម បំណុល ទុន ចំណាយ ចំណូល និង វិធីសាស្រ្តកត់ត្រាគណនី......7
១ ទ្រព្យសកម្ម......7
២ បំណុល......7
៣ ទុនសមាជិក......8
៤ ចំណូល......8
៥ ចំណាយ......9
វិធីសាស្រ្តកត់ត្រាគណនីទាំង៥......10
ឧទាហរណ៍អនុវត្តះ......12
មេរៀនទី៤ ប្រភេទបញ្ជីកត់ត្រាក្នុងគណនី......14
១ ប័ណ្ណចំណូល ប័ណ្ណចំណាយ និងបញ្ជីបេឡា......14
២ ទិន្នានុប្បវត្តិទូទៅ......18

៣ សៀវភៅមុខគណនី ឬ សៀវភៅធំ ........ 18
៤ តារាងតុល្យភាពសាកល្បង ........ 19
៥ តារាងតុល្យភាពកែតម្រូវ ........ 20
៦ របាយការណ៍ហិរញ្ញវត្ថុ ........ 20
ក តារាងតុល្យការ ........ 21
ខ តារាងរបាយការណ៍លទ្ធផល ........ 21
៧ បញ្ជីផ្សេងៗ ........ 21
មេរៀនទី ៥ ជំហានសំខាន់ៗក្នុងការចុះបញ្ជីគណនេយ្យ ........ 29
លំហាត់អនុវត្ត ទី១ ........ 30
លំហាត់អនុវត្ត ទី២ ........ 38
លំហាត់អនុវត្តទី ៣ ........ 46
គំរូនៃការវិភាគប្រតិបត្តិ ........ 58
I- ប័ណ្ណចំណូលជាសាច់ប្រាក់នៅក្នុងបេឡា (កត់ត្រាក្នុងប័ណ្ណចំណូល) ........ 58
II- ប័ណ្ណចំណាយជាសាច់ប្រាក់នៅក្នុងបេឡា (ធ្វើប័ណ្ណចំណាយ) ........ 59
III- ការចុះទិនានុប្បវត្តិប្រាក់ផ្ញើធនាគារ ........ 60
IV- ការចុះទិនានុប្បវត្តិអាជីវកម្មជំនឿទុកចិត្ត (មុខរបរឥណទាន) ........ 60
V- ការចុះទិនានុប្បវត្តិអាជីវកម្មផ្គត់ផ្គង់ ........ 61
បញ្ជីឈ្មោះគណនីក្នុងផ្នែកទាំង ៥ ........ 63

# មេរៀនទី១ អ្វីទៅជាការចុះបញ្ជីគណនេយ្យ ?

## ១ និយមន័យ

- **ការចុះបញ្ជី៖** ជាបច្ចេកទេស ឬវិធីសាស្ត្រនៃការចុះបញ្ជី ដើម្បីបង្កើតនូវរបាយការណ៍ហិរញ្ញវត្ថុ តាមរយៈប្រព័ន្ធនៃការចុះបញ្ជីគណនេយ្យ ដែលជនពាក់ព័ន្ធផលប្រយោជន៍ត្រូវការ ។ ការចុះបញ្ជីគណនេយ្យគ្រាន់តែជាផ្នែកមួយនៃដំណើរការការងាររបស់គណនេយ្យប៉ុណ្ណោះ។
- **គណនេយ្យ៖** គឺជាដំណើរការនៃការកត់ត្រា រាយការណ៍ ត្រួតពិនិត្យ វិភាគ និងបកស្រាយជាអាទិ៍ នូវព័ត៌មានហិរញ្ញវត្ថុដែលបានកត់ត្រាតាមរយៈការចុះបញ្ជីគណនេយ្យ ។
- **របាយការណ៍ហិរញ្ញវត្ថុ៖** រួមមាន តារាងតុល្យការ និង តារាងរបាយការណ៍លទ្ធផល ។
- **តារាងតុល្យការ៖** ជាតារាងដែលបង្ហាញនូវទ្រព្យសកម្ម បំណុល និងទុន ដោយមានរូបមន្ត

**ទ្រព្យសកម្ម = បំណុល + ទុន**

ឬ មានទម្រង់

| | |
|---|---|
| ទ្រព្យសកម្ម | បំណុល |
| | ទុន |

- **តារាងរបាយការណ៍លទ្ធផល** = របាយការណ៍ចំណេញ/ខាត ៖ បង្ហាញពីផលចំណេញ ឬខាតនៃប្រតិបត្តិការអាជីវកម្មក្នុងរយៈពេលមួយកំណត់ ។

**ចំណេញ/ខាត = ចំណូល - ចំណាយ**

## ២ គោលបំណងនៃការចុះបញ្ជីគណនេយ្យ

ការចុះបញ្ជីគណនេយ្យ សហគមន៍កសិកម្មមានគោលបំណង ៣ យ៉ាងគឺ៖

- ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិសហគមន៍ឲ្យបានត្រឹមត្រូវល្អ
- ដើម្បីគណនាចំណាយ ចំណូល និងធ្វើរបាយការណ៍ហិរញ្ញវត្ថុរបស់សហគមន៍
- ដើម្បីផ្តល់ទំនុកទុកចិត្តដល់សមាជិក និងអ្នកចង់រកស៊ីជាមួយសហគមន៍កសិកម្ម។

# ៣ ប្រភេទគណនេយ្យទាំង ២ប្រភេទ

**៣.១ គណនេយ្យឯកភាគ** (១) ៖ គឺគណនេយ្យដែលកត់ត្រាតែរាល់សកម្មភាពចំណូល,ចំណាយ ដើម្បីបង្ហាញពីការកើនឡើង និងថយចុះនៃសាច់ប្រាក់។ គណនេយ្យនេះច្រើន ប្រើនៅក្នុងអង្គការ, ស្ថាបន័រដ្ឋ គ្រួសារ ជាលក្ខណៈឯកជនឬផ្នែកអាជីវកម្មខ្នាតតូចដែលមិនតម្រូវឲ្យដាក់ទុនចូលហ៊ុនគ្នា។

**៣.២ គណនេយ្យទ្វេភាគ** ៖ គឺជាគណនេយ្យបង្ហាញថាប្រតិបត្តិការមួយត្រូវមានគណនីពីរកើតឡើង ឬ អង្គហេតុ១តែងតែមាន ***មូលហេតុ*** និង ***លទ្ធផល*** របស់វា។

អង្គហេតុ= ប្រតិបត្តិការ
- មូលហេតុ = គណនីទី១
- លទ្ធផល = គណនីទី២

ក្នុងគណនេយ្យទ្វេភាព គេកត់ត្រា ទាំងពីរ គឺ មូលហេតុ និង លទ្ធផល របស់ប្រតិបត្តិការសហគមន៍កសិកម្ម ។

គុណប្រយោជន៍នៃប្រព័ន្ធចុះបញ្ជីគណនេយ្យទ្វេភាគ គឺ ដើម្បីធានានូវភាពត្រឹមត្រូវ និងពេញលេញក្នុងការកត់ត្រារាល់ប្រតិបត្តិមុខរបរ ។ វាគឺជាប្រភពនៃព័ត៌មានហិរញ្ញវត្ថុដែលអាចទុកចិត្តបាន និងការវាយតម្លៃសុក្រិតចំពោះលក្ខខណ្ឌឬសកម្មភាពនៃមុខរបរ ។

➢ **ឧទាហរណ៍ទី១៖** ថ្ងៃទី១០/០៥/២០១៧ សហគមន៍កសិកម្មបានទទួលប្រាក់ភាគហ៊ុនសរុបចំនួន ៥,០០០,០០០រៀល ។

**ការកត់ត្រា**

អង្គហេតុ = ប្រតិបត្តិការ ➡ ប្រាក់ភាគហ៊ុន ៥,០០០,០០០រៀល

- មូលហេតុ = គណនីទី១ ➡ សមាជិកដាក់ហ៊ុន ៥,០០០,០០០រៀល
- លទ្ធផល = គណនីទី២ ➡ សហគមន៍ទទួលបានសាច់ប្រាក់ ៥,០០០,០០០៛

➢ **ឧទាហរណ៍ទី២៖** ថ្ងៃទី១១/០៥/២០១៧ សហគមន៍កសិកម្មបានឲ្យសមាជិកខ្ចីប្រាក់ចំនួន ២០០,០០០រៀល

**ការកត់ត្រា**

អង្គហេតុ = ប្រតិបត្តិការ → ឲ្យសមាជិកខ្ចី ២០០,០០០រៀល

- មូលហេតុ = គណនីទី១ → សមាជិកខ្ចីប្រាក់ ២០០,០០០រៀល
- លទ្ធផល = គណនីទី២ → សហគមន៍អស់សាច់ប្រាក់ ៥,០០០,០០០៛

➢ **ឧទាហរណ៍ទី៣៖** សហគមន៍បានយកប្រាក់ចំនួន ៥,៧០០,០០០រៀលទៅផ្ញើធនាគារ

- **លទ្ធផល = គណនី ៖ អស់សាច់ប្រាក់ ៥,៧០០,០០០**
- **មូលហេតុ = គណនី ៖ ដាក់ប្រាក់ផ្ញើធនាគារ ៥,៧០០,០០០**

➢ **ឧទាហរណ៍ទី៤៖** សហគមន៍កសិកម្មបានទិញអាហារសម្រន់សម្រាប់ប្រជុំប្រចាំខែ អស់ទឹកប្រាក់ ១០០,០០០រៀល ។

- **លទ្ធផល = គណនី ៖ អស់សាច់ប្រាក់ ១០០,០០០**
- **មូលហេតុ = គណនី ៖ ទិញអាហារសម្រន់ ៥០០,០០០**

➢ **ឧទាហរណ៍ទី៥៖** សហគមន៍បានទិញកុំព្យូទ័រ ១គ្រឿងតម្លៃ ១,២០០,០០០ ដោយសហគមន៍គ្មានថវិការក្នុងដៃក៏សម្រេចចិត្ត ដកប្រាក់ពីធនាគារបង់ឲ្យក្រុមហ៊ុនកុំព្យូទ័រ

- **លទ្ធផល= គណនី ៖ កុំព្យូទ័រ ១,២០០,០០០**
- **មូលហេតុ =គណនី ៖ ប្រាក់ផ្ញើធនាគារ ១,២០០,០០០**

➢ **ឧទាហរណ៍ទី៦៖** សហគមន៍កសិកម្មបានបញ្ជូលសមាជិកចំនួន ២នាក់ ទៅរៀនការគ្រប់គ្រងហិរញ្ញវត្ថុ អស់ប្រាក់សរុប ៧០០,០០០រៀល

- **លទ្ធផល = គណនី ៖ អស់សាច់ប្រាក់ ៧០០,០០០**
- **មូលហេតុ = គណនី ៖ ទៅរៀន ៧០០,០០០**

➢ **ឧទាហរណ៍ទី៧៖** សមាជិកសងប្រាក់ដើមកម្ចីឥណទានចំនួន ១,០០០,០០០រៀល និងការប្រាក់ ៥០,០០០រៀល ។

- **លទ្ធផល = គណនី ៖ ទទួលបានសាច់ប្រាក់ ១,០៥០,០០០**
- **មូលហេតុ = គណនី ៖ ប្រាក់ដើម ១,០០០,០០០**
- **មូលហេតុ = គណនី ៖ ការប្រាក់ ៥០,០០០**

➢ **ឧទាហរណ៍ទី៨៖** សហគមន៍ចំណាយទិញជី សរុបជាសាច់ប្រាក់ ៣,០០០,០០០រៀល ដោយបង់លុយ ២,០០០,០០០ ឲ្យក្រុមហ៊ុន និង ១,០០០,០០០រៀលទៀត សន្យាសងនៅបំណាច់ខែ

- **លទ្ធផល= គណនី= អស់សាច់ប្រាក់ ២,០០០,០០០**
- **មូលហេតុ = គណនី ៖ ទិញជី ៣,០០០,០០០**
- **មូលហេតុ = គណនី ៖ អ្នកផ្គត់ផ្គង់ =ជំពាក់ ១,០០០,០០០**

➢ **ឧទាហរណ៍ទី៩៖** សហគមន៍បានទទួលប្រាក់ឧបត្ថម្ភធនពីរដ្ឋចំនួន ២,០០០,០០០រៀល

- **លទ្ធផល= គណនី= អស់សាច់ប្រាក់ ២,០០០,០០០**
- **មូលហេតុ = គណនី ៖ អំណោយរដ្ឋ ៣,០០០,០០០**

➢ **ឧទាហរណ៍ទី១០៖** សហគមន៍បានទិញរថយន្តមួយគ្រឿងសម្រាប់ដឹកកសិផលក្នុងតម្លៃ ៣២,០០០,០០០រៀល

- **លទ្ធផល= គណនី= អស់សាច់ប្រាក់ ៣២,០០០,០០០**
- **មូលហេតុ = គណនី ៖ ទិញរថយន្ត ៣២,០០០,០០០**

# មេរៀនទី២ ប្រតិបត្តិការ និង គណនី

## ១ ប្រតិបត្តិការ

ប្រតិបត្តិការ គឺជាសកម្មភាពដែលទាក់ទងទៅនឹងទ្រព្យសកម្ម បំណុល ទុនសមាជិក ចំណូល និងចំណាយ ដែលត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីគណនេយ្យ ។

ឧទាហរណ៍៖

- ការដាក់ប្រាក់ឲ្យសមាជិកខ្ចី គឺធ្វើឲ្យសាច់ប្រាក់របស់សហគមន៍ត្រូវថយចុះ
- សម្ភារត្រូវចោរលួច ឬ អគារការិយាល័យត្រូវដួលរលំដោយខ្យល់ព្យុះ ជាដើម (ជាការខាតបង់) គេក៏ហៅវាថាជាប្រតិបត្តិការដែរ ។

**សកម្មភាពណាដែលមិនជះឥទ្ធិពលដល់ទ្រព្យ បំណុ ទុនសមាជិក ចំណូល និងចំណាយ គេមិនហៅថា ប្រតិបត្តិការ ទេក្នុងបញ្ជីគណនេយ្យ ។**

## ២ គណនី

### ២.១ អ្វីជាគណនី

គណនី គឺជាការដាក់ឈ្មោះលើសកម្មភាពនីមួយៗនៅក្នុងប្រតិបត្តិការ ហើយវាបានពីការកើនឡើង និងថយចុះនៃខ្លឹមសាររបស់វា ។

**ខ្លឹមសាររបស់គណនី**

១. ត្រូវមានឈ្មោះគណនី (ទ្រព្យសកម្ម បំណុល ទុន ចំណូល ចំណាយ)

២. ផ្នែកខាងឆ្វេងនៃអក្សរ T ហៅថា ឥណពន្ធ

៣. ផ្នែកខាងស្តាំនៃអក្សរ T ហៅថា ឥណទាន ។

**ទម្រង់គណនី** មានរាងជាអក្សរ ( T )



**សមតុល្យគណនី = សរុបខាងឥណពន្ធ - សរុបខាងឥណទាន**

ឬ

**សមតុល្យគណនី = សរុបខាងឥណទាន - សរុបខាងឥណពន្ធ**

## ២.២ គណនីទូទៅ

លេខគណនីដែលបានប្រើនៅក្នុងការងារជំនួញរបស់សហគមន៍កសិកម្មមានប្រហែល ២០០មុខហើយគេចែកជា ៥ក្រុមក្នុងនោះមានៈ

១. ផ្នែកគណនីទ្រព្យសកម្ម

២. ផ្នែកគណនីបំណុល

៣. ផ្នែកគណនីដើមទុន

៤. ផ្នែកចំណូល

៥. ផ្នែកចំណាយ ។

# មេរៀនទី៣ ទ្រព្យសកម្ម បំណុល ទុន ចំណាយ ចំណូល និង វិធីសាស្ត្រកត់ត្រាគណនីទាំង ៥

## ១ ទ្រព្យសកម្ម

ទ្រព្យសកម្ម គឺជាអ្វីដែលមានតម្លៃជាលក្ខណៈសេដ្ឋកិច្ច និងអាចគិតជាសាច់ប្រាក់បាន ។ ទ្រព្យសកម្មរបស់សហគមន៍មាន ០២ គឺ៖

១.ទ្រព្យចល័ត មាន៖

- សាច់ប្រាក់ គឺជាប្រាក់ក្នុងដៃ ឬរក្សាទុកក្នុងទូដែកសុវត្ថិភាព
- ប្រាក់ផ្ញើធនាគារ
- ប្រាក់ឲ្យសមាជិកសហគមន៍ខ្ចី
- បន្ទុកពិនិត្យមុន (ប្រាក់កក់មុនសម្រាប់ទិញ ឬ ជួលអ្វីមួយ)
- គណនីអតិថិជនឬ ប្រាក់ដែលគេជំពាក់ត្រូវទារ
- ទ្រព្យក្នុងស្តុក ឬ ទំនិញក្នុងស្តុកឃ្លាំង

២.អចល័តទ្រព្យ មាន៖ អគារ ម៉ាស៊ីន ដី តុ កៅអី កុំព្យូទ័រ .......។ល។

**វិធីសាស្ត្រក្នុងការតត់ត្រា**

| ទ្រព្យសកម្ម | |
|---|---|
| កើនឡើង | ថយចុះ |

## ២ បំណុល

បំណុល គឺជាប្រាក់ ឬ វត្ថុដែលសហគមន៍បានខ្ចីពីធនាគារ ឬ ពីបុគ្គលណាម្នាក់ សម្រាប់យកមកបម្រើឲ្យមុខរបរជំនួញសហគមន៍ ហេតុដូច្នេះសហគមន៍ត្រូវតែសងគេវិញតាមពេលកំណត់ជាក់លាក់មួយ ដោយមានការប្រាក់ ឬ គ្មានការប្រាក់ ។

ប្រភេទបំណុលដែលសហគមន៍ជំពាក់គេរួមមាន៖

- ប្រាក់កម្ចី (ពីធនាគារ...)
- ប្រាក់បញ្ញើសន្សំរបស់សមាជិក (ប្រាក់សន្សំ)
- ប្រាក់បញ្ញើសន្សំមានការកំណត់របស់សមាជិក ឬ បុគ្គលណាម្នាក់

- គណនីអ្នកផ្គត់ផ្គង់ ឬ ប្រាក់ទិញទំនិញជឿគេ ( ) និង
- ប្រាក់មិនបង់ថ្លៃសេវាកម្មនានាដូចជា អគ្គិសនី ទឹក ទូរសព្ទ ជួលដី ជួលឃ្លាំង។ល។

**វិធីសាស្ត្រក្នុងការតក់ត្រា**

| បំណុល | |
|---|---|
| ថយចុះ | កើនឡើង |

## ៣ ទុនសមាជិក

ទុន គឺជាបរិមាណទឹកប្រាក់ ឬ ភាគហ៊ុនដែលសមាជិកបានដាក់ក្នុងសហគមន៍កសិកម្ម ដើម្បីឲ្យសហគមន៍ប្រកបមុខរបរអ្វីមួយ ហើយសហគមន៍មិនចាំបាច់សងទុននោះទៅសមាជិកវិញទេនៅពេលរកស៊ីខាត ប៉ុន្តែសហគមន៍ត្រូវសងប្រាក់ភាគហ៊ុនវិញនៅពេលសមាជិកនោះលាឈប់ ។

ប្រភេទដើមទុនៈ

- ប្រាក់ភាគហ៊ុនរបស់សមាជិក
- ប្រាក់សមាជិកភាពរបស់សមាជិក
- ប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាល
- ប្រាក់អំណោយអង្គការ សប្បុរសជន
- មូលនិធិបម្រុង របស់សហគមន៍ប្រចាំឆ្នាំ (២០%) ជារៀងរាល់ឆ្នាំ
- មូលនិធិបណ្តុះបណ្តាលប្រចាំឆ្នាំ (៣%)
- ប្រាក់អតិរេកមិនទាន់ចាត់ចែង ឬ ប្រាក់ចំណេញមិនទាន់បែងចែងដល់សមាជិក ។

**វិធីសាស្ត្រក្នុងការតក់ត្រា**

| ទុន | |
|---|---|
| ថយចុះ | កើនឡើង |

## ៤ ចំណូល

ចំណូល គឺជាប្រាក់ចំណេញដុលដែលបានមកពីការធ្វើអាជីវកម្មសេដ្ឋកិច្ចរបស់សហគមន៍កសិកម្ម។

ប្រភេទចំណូល៖

- ការប្រាក់នៃប្រាក់ផ្ញើធនាគារ
- ការប្រាក់នៃប្រាក់ឲ្យគេខ្ចី
- ចំណូលពីការលក់ទំនិញ
- កម្រៃជើងសារទទួលបាន
- ចំណូលពីសេវាកម្មផ្សេងៗ ។

**វិធីសាស្ត្រក្នុងការតក់ត្រា**

| ចំណូល | |
|---|---|
| លុបចោល | កើតមាន |

# ៥ ចំណាយ

ចំណាយគឺជាការថយចុះនៃទ្រព្យធនរបស់សហគមន៍កសិកម្មដើម្បីធ្វើប្រតិបត្តិការ និងសម្រេចគោលដៅរបស់សហគមន៍ ។

ប្រភេទចំណាយ៖

- ការប្រាក់នៃប្រាក់បញ្ញើ
- ការប្រាក់កម្ចី
- ចំណាយទិញទំនិញ
- ចំណាយលើការធ្វើដំណើរ
- ចំណាយលើទូរគមនាគមន៍
- ចំណាយលើកដាក់លីសែង
- ចំណាយផ្សេងៗ ។

**វិធីសាស្ត្រក្នុងការតក់ត្រា**

| ចំណាយ | |
|---|---|
| កើតមាន | លុបចោល |

# វិធីសាស្ត្រកត់ត្រាគណនីទាំង៥ ឬ
# វិធានកត់ត្រា ឥណពន្ធ និងឥណទាន

ចំពោះផ្នែកគណនីទាំង ៥ រួមមាន គណនីទ្រព្យសកម្ម គណនីបំណុល គណនីទុនសមាជិក គណនីចំណាយ និងគណនីចំណូល គឺត្រូវគោរពតាមគោលការណ៍នៃការកត់ត្រាឥណពន្ធ និងឥណទាន ដូចខាងក្រោម៖

ទ្រព្យសកម្ម

| កើនឡើង | ថយចុះ |
|---|---|

បំណុល

| ថយចុះ | កើនឡើង |
|---|---|

ទុន

| ថយចុះ | កើនឡើង |
|---|---|

ចំណាយ

| កើតមាន | លុបចោល |
|---|---|

ចំណូល

| លុបចោល | កើតមាន |
|---|---|

# បញ្ជីឈ្មោះគណនីក្នុងផ្នែកទាំង ៥

| ផ្នែក | ឈ្មោះគណនី | ការពន្យល់អំពីខ្លឹមសារ |
|---|---|---|
| ទ្រព្យសកម្ម | សាច់ប្រាក់ ឬ បេឡា<br>គណនីប្រាក់ផ្ញើធនាគារ<br>ប្រាក់ឲ្យខ្ចីមានលិខិតសន្យា<br>គណនីអតិថិជន ឬ គណនីត្រូវទារ<br>ដីធ្លី<br>អគារ<br>ឧបករណ៍ការិយាល័យ<br>សម្ភារៈដឹកជញ្ជូន<br>សម្ភារៈផ្សេងៗ | ប្រាក់ដែលមាននៅក្នុងដៃ (រូបិយប័ណ្ណ ជាដើម)<br>គណនីដែលផ្ញើនៅតាមស្ថាប័នហិរញ្ញវត្ថុដូចជាធនាគារជាដើម<br>ប្រាក់ឲ្យសមាជិកខ្ចី<br>ថ្លៃលក់ទំនិញផ្គត់ផ្គង់ តែមិនទាន់បានទទួលប្រាក់ (លក់ទំនិញជឿជូនអតិថិជន)<br>ដីដែលជាកម្មសិទ្ធិរបស់សហគមន៍កសិកម្ម<br>អគារដែលជាកម្មសិទ្ធិរបស់សហគមន៍កសិកម្ម<br>តុ និងកុំព្យូទ័រជាដើមដែលជាកម្មសិទ្ធិរបស់សហគមន៍កសិកម្ម<br>សម្ភារៈដឹកជញ្ជូនដែលជាកម្មសិទ្ធិរបស់សហគមន៍កសិកម្ម |
| បំណុល | ប្រាក់បញ្ញើមានកាលកំណត់ ឬ បញ្ញើសន្សំ<br>ប្រាក់ខ្ចីពីធនាគារ<br>គណនីអ្នកផ្គត់ផ្គង់ ឬ គណនីត្រូវសងប្រាក់មិនទាន់បង់ | ប្រាក់បញ្ញើរបស់សមាជិកជាដើម (បញ្ញើក្រៅពីសមាជិកក៏មានដែរ)<br>ប្រាក់ដែលខ្ចីមកពីធនាគារ<br>ថ្លៃទិញទំនិញផ្គត់ផ្គង់ តែមិនទាន់បានបង់ (ទិញទំនិញជឿ)<br>គណនីអ្នកផ្គត់ផ្គង់ បំណុលក្រៅពីថ្លៃទិញជឿនូវទំនិញសម្រាប់លក់ |
| ទុន<br>សហគមន៍ | ប្រាក់ចូលហ៊ុន<br>ប្រាក់សមាជិកភាព<br>មូលនិធិបំរុង<br>ទុនបណ្តុះបណ្តាល<br>អតិរេកមិនទាន់ចាត់ចែង<br>អំណោយពីសប្បុរសជន និងអង្គការ<br>អំណោយពីរាជរដ្ឋាភិបាល | បរិមាណទឹកប្រាក់ដែលសមាជិកដាក់ទុនវិនិយោគ<br>ប្រាក់បង់ចូលជាពីសមាជិក<br>ប្រាក់ដែលត្រូវដកពីប្រាក់ចំណេញសុទ្ធសម្រាប់បំរុងទុក ២០% ប្រចាំឆ្នាំ<br>ប្រាក់ដែលត្រូវដកពីប្រាក់ចំណេញសុទ្ធសម្រាប់បំរុងទុក ០៣% ប្រចាំឆ្នាំ<br>ប្រាក់ចំណេញសុទ្ធបានពីមុខរបរសហគមន៍<br>ប្រាក់អំណោយពីសប្បុរសជន និងអង្គការនានា<br>ប្រាក់អំណោយពីរដ្ឋ |
| ចំណូល | ការប្រាក់នៃប្រាក់ផ្ញើធនាគារ<br>ការប្រាក់នៃប្រាក់ឲ្យគេខ្ចី<br>ចំណូលពីការលក់ទំនិញ<br>កម្រៃជើងសារទទួលបាន<br>ចំណូលពីសេវាកម្មផ្សេងៗ | បរិមាណការប្រាក់បានមកពីប្រាក់ផ្ញើនៅធនាគារ<br>បរិមាណការប្រាក់បានមកពីប្រាក់ដែលឲ្យគេខ្ចី<br>ថ្លៃលក់ទំនិញផ្គត់ផ្គង់<br>បរិមាណកម្រៃជើងសារដែលទទួលបានដោយការផ្តល់សេវាកម្ម |
| ចំណាយ | ការប្រាក់នៃប្រាក់បញ្ញើ<br>ការប្រាក់កម្ចី<br>ចំណាយទិញទំនិញ<br>ចំណាយលើការធ្វើដំណើរ<br>ចំណាយលើទូរគមនាគមន៍<br>ចំណាយលើកដាក់លីសែង<br>ចំណាយផ្សេងៗ | ការប្រាក់នៃប្រាក់បញ្ញើ<br>ការប្រាក់នៃប្រាក់កម្ចី<br>ថ្លៃទិញទំនិញសម្រាប់ផ្គត់ផ្គង់<br>ថ្លៃធ្វើដំណើរទៅធ្វើការខាងក្រៅ និងថ្លៃធ្វើដំណើរទៅធ្វើការនៅការិយាល័យ<br>ថ្លៃទំនាក់ទំនងដូចជាប្រៃសណីយ៍ និងទូរសព្ទជាដើម<br>ថ្លៃចំណាយលើកម្មករ<br>ថ្លៃចំណាយផ្សេងទៀត |

# ឧទាហរណ៍អនុវត្តៈ

**ចំណាំ**

អង្គហេតុ= ប្រតិបត្តិការ
- មូលហេតុ = គណនីទី១
- លទ្ធផល = គណនីទី២

**១. សហគមន៍បានទទួលប្រាក់ភាគហ៊ុនពីសមាជិកចំនួន ៥លានរៀល ។**

វិភាគៈ រកមូលហេតុ និង រកលទ្ធផលនៃប្រតិបត្តិការ ?

- មូលហេតុ = សមាជិកដាក់ប្រាក់ភាគហ៊ុន ឬទិញហ៊ុន = ប្រាក់ភាគហ៊ុន
- លទ្ធផល = សហគមន៍មានប្រាក់ ឬទទួលបានប្រាក់ = សាច់ប្រាក់

**ទ្រព្យសកម្ម**

| កើនឡើង | ថយចុះ |
|---|---|

**ទុន**

| ថយចុះ | កើនឡើង |
|---|---|

សាច់ប្រាក់

| | |
|---|---|
| ៥,000,000 | |

ប្រាក់ភាគហ៊ុន

| | |
|---|---|
| | ៥,000,000 |

ឬ
- សាច់ប្រាក់ ៥,000,000រៀល
- ប្រាក់ភាគហ៊ុន ៥,000,000រៀល

**២. សហគមន៍ខ្ចីប្រាក់ចំនួន ១0,000,000រៀល ពីធនាគារ ។**

- មូលហេតុ= ខ្ចីប្រាក់ធនាគារ=ប្រាក់កម្ចី
- លទ្ធផល= ទទួលបានសាច់ប្រាក់= សាច់ប្រាក់

**បំណុល**

| ថយចុះ | កើនឡើង |
|---|---|

សាច់ប្រាក់

| | |
|---|---|
| ១0,000,000 | |

ប្រាក់កម្ចីធនាគារ

| | |
|---|---|
| | ១0,000,00 |

ឬ
- សាច់ប្រាក់ ១0,000,000រៀល
- ប្រាក់កម្ចីធនាគារ ១0,000,000រៀល

**៣. សហគមន៍បានចំណាយប្រាក់អស់ ៥០,០០០ ស្រាប់ការប្រជុំប្រចាំខែ ។**

- មូលហេតុ = ចំណាយប្រជុំ
- លទ្ធផល = អស់ប្រាក់ = សាច់ប្រាក់

**ចំណាយ**

| កើតមាន | លុបចោល |
|---|---|

| ចំណាយប្រជុំ | |
|---|---|
| ៥០,០០០ | |

| សាច់ប្រាក់ | |
|---|---|
| | ៥០,០០០ |

ឬ - សាច់ប្រាក់ ៥០,០០០រៀល

- ចំណាយប្រជុំ ៥០,០០០រៀល

**៤. សហគមន៍ទិញម៉ូតូមួយគ្រឿងអស់ប្រាក់ចំនួន ៦,០០០,០០០រៀល ។**

- មូលហេតុ = ទិញម៉ូតូ = ម៉ូតូ
- លទ្ធផល = អស់ប្រាក់ = សាច់ប្រាក់

| ម៉ូតូ | |
|---|---|
| ៦,០០០,០០០ | |

| សាច់ប្រាក់ | |
|---|---|
| | ៦,០០០,០០០ |

ឬ - សាច់ប្រាក់ ៦,០០០,០០០រៀល

- ម៉ូតូ ៦,០០០,០០០រៀល

**៥. សហគមន៍ទទួលបានចំណូលពីការប្រាក់ចំនួន ២,៥០០,០០០រៀល ។**

- មូលហេតុ = ទទួលបានចំណូលពីការប្រាក់ = ចំណូលការប្រាក់
- លទ្ធផល = ទទួលបានប្រាក់ = សាច់ប្រាក់

**ចំណូល**

| លុបចោល | កើតមាន |
|---|---|

| សាច់ប្រាក់ | |
|---|---|
| ២,៥០០,០០០ | |

| ចំណូលការប្រាក់ | |
|---|---|
| | ២,៥០០,០០០ |

ឬ - សាច់ប្រាក់ ២,៥០០,០០០

- ចំណូលការប្រាក់ ២,៥០០,០០០

# មេរៀនទី៤ ប្រភេទបញ្ជីកត់ត្រាក្នុងគណនី

## ១ ប័ណ្ណចំណូល ប័ណ្ណចំណាយ និងបញ្ជីបេឡា

**ក ប័ណ្ណចំណូល** គឺកត់ត្រារាល់ចំណូលជាសាច់ប្រាក់ទាំងឡាយរបស់សហគមន៍ ពេលគឺសហគមន៍ទទួលបានសាច់ប្រាក់ពីអ្វីមួយ ។

ប័ណ្ណចំណូលសម្រាប់មួយប្រតិបត្តិការ គឺមាន ៣សន្លឹកដូចគ្នា តែខុសពណ៌គ្នា៖

- ពណ៌ស៖ សន្លឹកទី១ សម្រាប់ប្រគល់ឲ្យអ្នកដែលបានផ្តល់ប្រាក់
- ពណ៌ផ្កាឈូក៖ សន្លឹកទី២ សម្រាប់ចម្លងចូលក្នុងបញ្ជីបេឡា/សាច់ប្រាក់
- ពណ៌បៃតងខ្ចី៖ សន្លឹកទី៣ សម្រាប់រក្សាទុកក្នុងក្បាលបញ្ជីដើម្បីធ្វើការផ្ទៀងផ្ទាត់

**ប័ណ្ណចំណូល**

សហគមន៍កសិកម្ម....................................... លេខ..................

ភូមិ........................ឃុំ...............................ស្រុក...................

ខេត្ត.............................. ទឹកប្រាក់ចំនួន [ ]

បានទទួលពីលោក លោកស្រី.........................................អាស័យដ្ឋាន.........................................................

អត្ថន័យខ្ទង់ប្រាក់ចំណូល...........................................................................................................................

ទឹកប្រាក់ទទួលបាន(ជាអក្សរ)......................................................................................................................

ថ្ងៃទី ខែ ឆ្នាំ២០១

ប្រធានសហគមន៍ ប្រធានត្រួតពិនិត្យ បេឡា អ្នកប្រគល់ប្រាក់ អ្នកសរសេរប័ណ្ណ

**ប័ណ្ណចំណូល**

សហគមន៍កសិកម្ម....................................... លេខ..................

ភូមិ........................ឃុំ...............................ស្រុក...................

ខេត្ត.............................. ទឹកប្រាក់ចំនួន [ ]

បានទទួលពីលោក លោកស្រី.........................................អាស័យដ្ឋាន.........................................................

អត្ថន័យខ្ទង់ប្រាក់ចំណូល...........................................................................................................................

ទឹកប្រាក់ទទួលបាន(ជាអក្សរ)......................................................................................................................

ថ្ងៃទី ខែ ឆ្នាំ២០១

ប្រធានសហគមន៍ ប្រធានត្រួតពិនិត្យ បេឡា អ្នកប្រគល់ប្រាក់ អ្នកសរសេរប័ណ្ណ

**ប័ណ្ណចំណូល**

សហគមន៍កសិកម្ម...................................... លេខ..................

ភូមិ.......................ឃុំ...............................ស្រុក...................

ខេត្ត.............................. ទឹកប្រាក់ចំនួន

បានទទួលពីលោក លោកស្រី.........................................អាស័យដ្ឋាន........................................................

អត្ថន័យខ្ទង់ប្រាក់ចំណូល...........................................................................................................

ទឹកប្រាក់ទទួលបាន(ជាអក្សរ)......................................................................................................

ថ្ងៃទី ខែ ឆ្នាំ២០១

ប្រធានសហគមន៍ ប្រធានត្រួតពិនិត្យ បេឡា អ្នកប្រគល់ប្រាក់ អ្នកសរសេរប័ណ្ណ

**ខ ប័ណ្ណចំណាយ** គឺត្រូវកត់ត្រារាល់ចំណាយសាច់ប្រាក់ក្នុងដៃទាំងឡាយរបស់សហគមន៍ ពោលគឺសហគមន៍បានយកសាច់ប្រាក់ទៅចាយវាយលើអ្វីមួយ ។

ប័ណ្ណចំណាយសម្រាប់មួយប្រតិបត្តិការ គឺមាន ៣សន្លឹកដូចគ្នា តែខុសពណ៌គ្នា៖

- ពណ៌ស៖ សន្លឹកទី១ សម្រាប់ប្រគល់ឲ្យអ្នកទទួលប្រាក់
- ពណ៌ផ្កាឈូក៖ សន្លឹកទី២ សម្រាប់ចម្លងចូលក្នុងបញ្ជីបេឡា/សាច់ប្រាក់
- ពណ៌បៃតងខ្ចី៖ សន្លឹកទី៣ សម្រាប់រក្សាទុកក្នុងក្បាលបញ្ជីដើម្បីធ្វើការផ្ទៀងផ្ទាត់

**ប័ណ្ណចំណាយ**

សហគមន៍កសិកម្ម...................................... លេខ..................

ភូមិ.......................ឃុំ...............................ស្រុក...................

ខេត្ត.............................. ទឹកប្រាក់ចំនួន

បានបើកជូនលោក លោកស្រី.......................................អាស័យដ្ឋាន........................................................

អត្ថន័យខ្ទង់ប្រាក់ចំណាយ.........................................................................................................

ទឹកប្រាក់ចំណាយ(ជាអក្សរ).......................................................................................................

ថ្ងៃទី ខែ ឆ្នាំ២០១

ប្រធានសហគមន៍ ប្រធានត្រួតពិនិត្យ បេឡា អ្នកទទួល អ្នកសរសេរប័ណ្ណ

**ប័ណ្ណចំណាយ**

សហគមន៍កសិកម្ម....................................... លេខ..................

ភូមិ.......................ឃុំ...............................ស្រុក...................

ខេត្ត.............................. ទឹកប្រាក់ចំនួន

បានបើកជូនលោក លោកស្រី.......................................អាស័យដ្ឋាន..........................................................................

អត្ថន័យខ្ទង់ប្រាក់ចំណាយ........................................................................................................................

ទឹកប្រាក់ចំណាយ(ជាអក្សរ)...................................................................................................................

ថ្ងៃទី ខែ ឆ្នាំ២០១

ប្រធានសហគមន៍ ប្រធានត្រួតពិនិត្យ បេឡា អ្នកទទួល អ្នកសរសេរប័ណ្ណ

**ប័ណ្ណចំណាយ**

សហគមន៍កសិកម្ម....................................... លេខ..................

ភូមិ.......................ឃុំ...............................ស្រុក...................

ខេត្ត.............................. ទឹកប្រាក់ចំនួន

បានបើកជូនលោក លោកស្រី.......................................អាស័យដ្ឋាន..........................................................................

អត្ថន័យខ្ទង់ប្រាក់ចំណាយ........................................................................................................................

ទឹកប្រាក់ចំណាយ(ជាអក្សរ)...................................................................................................................

ថ្ងៃទី ខែ ឆ្នាំ២០១

ប្រធានសហគមន៍ ប្រធានត្រួតពិនិត្យ បេឡា អ្នកទទួល អ្នកសរសេរប័ណ្ណ

## គ បញ្ជីបេឡា ឬ បញ្ជីសាច់ប្រាក់

បញ្ជីបេឡា គឺបញ្ជីកត់ត្រានូវរាល់ប្រតិបត្តិការណាដែលជាសាច់ប្រាក់ចូល និងសាច់ប្រាក់ចេញពីក្នុងដៃផ្ទាល់ ភាគច្រើនគេតែងតែស្រង់ចេញពីប័ណ្ណចំណូលនិងប័ណ្ណចំណាយ។

**ចំណាំ៖** បើសាច់ប្រាក់ណាមិនបានទទួលផ្ទាល់ដៃ ឬចេញពីក្នុងដៃទេ នោះ គេមិនចុះចូលក្នុងបញ្ជីបេឡាទេ។

# បញ្ជីបេឡា

សហគមន៍កសិកម្ម...................... លេខសន្លឹក..................

ភូមិ.................ឃុំ....................................

ស្រុក......................ខេត្ត............................

| ថ្ងៃ ខែ ឆ្នាំ | លេខប័ណ្ណ | | បរិយាយ | ចំនួនទឹកប្រាក់ | | ប្រាក់នៅសល់ |
|---|---|---|---|---|---|---|
| | ចំណូល | ចំណាយ | | ចំណូល | ចំណាយ | |
| | | | យោងសមតុល្យដើមគ្រា | | | ២០០.០០០ |
| ០៥/០១/០១៤ | ០០១ | | ប្រាក់ចូលហ៊ុន | ១០,០០០ | | |
| ១០/១/០១៤ | | ០០១ | បង់ថ្លៃភ្លើង | | ៥,០០០ | |
| ១២/០១/០១៤ | | ០០២ | ប្រាក់ផ្ញើធនាគា | | ៥៥,០០០ | |
| ១៤/០១/០១៤ | ០០២ | | ចំណូលការប្រាក់ផ្ញើធនាគា | ១០,០០០ | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | សរុប | ២០,០០០ | ៥៥,០០០ | ១៦៥,០០០ |

# ២ ទិន្នានុប្បវត្តិទូទៅ

## ទិន្នានុប្បវត្តិទូទៅ

| កាលបរិច្ឆេទ | | ឈ្មោះគណនី និងបរិយាយ | ឥណពន្ធ | ឥណទាន |
|---|---|---|---|---|
| ខែ | ថ្ងៃទី | | | |
| ឧសភា | ១០ | សាច់ប្រាក់ | ៥០០,០០០ | |
| | | ប្រាក់សមាជិកភាព | | ៥០០,០០០ |
| | | (សមាជិកបង់ប្រាក់សមាជិកភាព) | | |
| ឧសភា | ១០ | សាច់ប្រាក់ | ៥,០០០,០០០ | |
| | | ប្រាក់ភាគហ៊ុន | | ៥,០០០,០០០ |
| | | (សមាជិកដាក់ហ៊ុនចូលសហគមន៍) | | |
| | | | | |

# ៣ សៀវភៅមុខគណនី ឬ សៀវភៅធំ

សៀវភៅមុខគណនីគឺជាសៀវភៅកត់ត្រាសរុបលទ្ធផលទៅតាមមុខគណនីនីមួយៗក្នុងផ្នែកទាំង៥នៃគណនី។

## សៀវភៅមុខគណនី

**មុខគណនី៖ ប្រាក់សមាជិកភាព** គិតត្រឹមថ្ងៃទី....៣១....ខែ.ឧសភា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មេសា | ៣០ | យោងសមតុល្យដើមគ្រា(សល់ពីខែមុន) | | | 0 |
| ឧសភា | ១០ | (សមាជិកបង់ប្រាក់សមាជិកភាព) | | ៥០០,០០០ | |
| | | | | | |
| | | | | | |
| | | សរុប | 0 | ៥០០,០០០ | ៥០០,០០០ |

## ៤ តារាងតុល្យភាពសាកល្បង

តារាងតុល្យភាពសាល្បង គឺជាតារាងសម្រាប់ផ្ទៀងផ្ទាត់នូវរាល់សកម្មភាពដែលបានចុះបញ្ជី (សៀវភៅធំ ) កន្លងមក ថាតើវាបានត្រឹមត្រូវហើយឬនៅ ដោយពិនិត្យទៅលើផ្នែកឥណពន្ធស្មើផ្នែកឥណទាន។

**រូបមន្ត៖**

| |
|---|
| ទ្រព្យសកម្ម + ចំណាយ = បំណុល + ដើមទុន + ចំណូល |

**ទម្រង់តារាងតុល្យភាពសាកល្បង**

| | |
|---|---|
| ទ្រព្យសកម្ម | បំណុល |
| | ទុន |
| ចំណាយ | ចំណូល |

**ចំណាំ៖** តារាងតុល្យភាពសាកល្បង គឺបានមកពីការស្រង់ទិន្នន័យក្នុងកូឡោនសមតុល្យ (សល់ចុងខែ) នៃសៀវភៅធំ ឬ មុខគណនីនីមួយៗ បញ្ចូលក្នុងតារាងតុល្យភាពសាកល្បង ។

**<u>តារាងតុល្យភាពសាកល្បង</u>**

ត្រឹមថ្ងៃទី៣១ ខែ មីនាឆ្នាំ២០១៧

| ទ្រព្យសកម្ម | សមតុល្យ | បំណុល | សមតុល្យ |
|---|---|---|---|
| សាច់ប្រាក់ | ១៦៥.០០០ | ប្រាក់កម្ចី | ៤០០.០០០ |
| ប្រាក់ផ្ញើធនាគារ | ២៥០.០០០ | ប្រាក់ជំពាក់គេ | ៤៥០.០០០ |
| ប្រាក់ឲ្យគេខ្ចី | ៥០.០០០ | ទុនសហគមន៍ | |
| ប្រាក់គេជំពាក់ត្រូវទារ | ១០០.០០០ | ប្រាក់ភាគហ៊ុន | ២៤០.០០០ |
| រំលស់អចនៈទ្រព្យ | ៦០០.០០០ | | |
| ចំណាយ | ៨៥.០០០ | ចំណូល | ១៦០.០០០ |
| សរុប | ១.២៥០.០០០ | សរុប | ១.២៥០.០០០ |

# ៥ តារាងតុល្យភាពកែតម្រូវ

តារាងតុល្យភាពកែតម្រូវ គឺជាតារាងសរុបអ្វីដែលនៅសល់ក្នុងខែនេះ និងអ្វីដែលបានកែតម្រូវ ដើម្បីបិទបញ្ជី និងស្រង់បញ្ចូលទៅក្នុងតារាងតុល្យការ ។ តារាងតុល្យភាពកែតម្រូវនេះ គឺគេធ្វើវា នៅពេលមានប្រតិបត្តិការណាមួយដែលភ្លេច ឬមិនទាន់បានចុះក្នុងទិន្នានុប្បវត្តទូទៅ និង សៀវភៅធំឬមុខគណនី ។

## តារាងតុល្យភាពកែតម្រូវ

| ឈ្មោះគណនី | តារាងតុល្យភាពសមតុល្យ | | ទិន្នានុប្បវត្តិកែតម្រូវដើម្បីបិទបញ្ជី | | សមតុល្យក្រោយកែតម្រូវ | |
|---|---|---|---|---|---|---|
| | ឥណពន្ធ | ឥណទាន | ឥណពន្ធ | ឥណទាន | ឥណពន្ធ | ឥណទាន |
| ១. ទ្រព្យសកម្ម | | | | | | |
| សាច់ប្រាក់ | ៛៥,៥០០,០០០ | | | | ៛៥,៥០០,០០០ | |
| ២. បំណុល | | | | | | |
| ៣. ទុន | | | | | | |
| ប្រាក់សមាជិកភាព | | ៛៥០០,០០០ | | | | ៛៥០០,០០០ |
| ប្រាក់ភាគហ៊ុន | | ៛៥,០០០,០០០ | | | | ៛៥,០០០,០០០ |
| ៤. ចំណូល | | | | | | |
| ៥. ចំណាយ | | | | | | |
| សរុប | ៛៥,៥០០,០០០ | ៛៥,៥០០,០០០ | 0 | 0 | ៛៥,៥០០,០០០ | ៛៥,៥០០,០០០ |

# ៦ របាយការណ៍ហិរញ្ញវត្ថុ



### ក    តារាងតុល្យការ

**តារាងតុល្យការៈ** ជាតារាងដែលបង្ហាញនូវទ្រព្យសកម្ម បំណុល និងទុន ដោយមានរូបមន្ត

| |
|---|
| **ទ្រព្យសកម្ម = បំណុល + ទុន** |

ឬ មានទម្រង់

| | |
|---|---|
| ទ្រព្យសកម្ម | បំណុល |
| | ទុន |

### ខ    តារាងរបាយការណ៍លទ្ធផល

**តារាងរបាយការណ៍លទ្ធផល** = របាយការណ៍ចំណេញ/ខាត ៖ បង្ហាញពីផលចំណេញ ឬ ខាតនៃប្រតិបត្តិការអាជីវកម្មក្នុងរយៈពេលមួយកំណត់ ។

| |
|---|
| **ចំណេញ/ខាត = ចំណូល - ចំណាយ** |

**ទម្រង់**

## ៧    បញ្ជីផ្សេងៗ

ក្រៅពីបញ្ជីទាំងនោះ នៅមានបញ្ជី ឬឯកសារពាក់ព័ន្ធមួយចំនួនទៀតសម្រាប់យកមកធ្វើការបិទបញ្ជីគណនេយ្យនេះ ។ បញ្ជីទាំងនោះរួមមាន ៖

- បញ្ជីតាមដានសំណងឥណទាន
- បញ្ជីតាមដានបំណុលអ្នកផ្គត់ផ្គង់ឬប្រាក់ត្រូវសង( ទិញទំនិញជឿ )
- បញ្ជីតាមដានបំណុលអតិថិជនប្រាក់ត្រូវទារ( លក់ទំនិញជឿ )
- សៀវភៅកុងធនាគារ( ប្រាក់ផ្ញើរធនាគារ )
- បញ្ជីទំនិញក្នុងស្តុក,សាលាកប័ត្រឃ្លាំង( បញ្ជីទំនិញសល់ក្នុងឃ្លាំង )

**ទម្រង់បញ្ជីតាមដានសំណងឥណទាន ៖** គឺជាបញ្ជីកត់ត្រានូវរាល់ប្រតិបត្តិការសហគមន៍កសិកម្មផ្តល់ប្រាក់កម្ចីឲ្យសមាជិក ដោយគិតការប្រាក់តាមគោលការរបស់សហគមន៍។

**ចំណាំ៖** បញ្ជីនេះគេតែងតែស្រង់ចេញពីកិច្ចសន្យាខ្ចីសងរបស់សមាជិក ហើយកិច្ចសន្យានេះមានច្រើនប្រភេទទៅតាមសហគមន៍ដូចជា៖ (កិច្ចសន្យាខ្ចីសងការងាប់,កិច្ចសន្យាខ្ចីសងការរស់,កិច្ចសន្យាបណ្តាក់ពូជ,កិច្ចសន្យាសងរំលស់,ផ្សេងៗ)។

## សហគមន៍កសិកម្ម.........................

## របាយការណ៍តាមដានសំណងឥណទាន

លេខកូដភូមិ................... ប្រចាំខែ..............................ឆ្នាំ.......................

| ល.រ | ឈ្មោះសមាជិក | ភេទ | កាលបរិច្ឆេទខ្ចី | ចំនួនប្រាក់ខ្ចី | ប្រាក់ដើមបានបងរួច | ប្រាក់ជំពាក់ខែមុខ | | ប្រាក់ត្រូវបង់ខែនេះ | | | សមតុល្យ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ប្រាក់ដើមត្រូវបង់ | ការប្រាក់ | ប្រាក់ដើមត្រូវបង់ | ការប្រាក់ | សរុប | ប្រាក់ដើមត្រូវបង់ | ការប្រាក់ | សរុប |
| 1 | សៅ សុខា | | ១៣ មិថុនា | 1,300,000 | | | 26,000 | | 26,000 | 26,000 | | 52,000 | 52,000 |
| 2 | សុខ នី | | ១១មិថុនា | 3,200,000 | | | | | 64,000 | 64,000 | | 64,000 | 64,000 |
| 3 | មីង រី | | ៧ កក្កដា | 2,000,000 | | | | | 40,000 | 40,000 | | 40,000 | 40,000 |
| 4 | ពូសាក់ | | ៤ កក្កដា | 1,500,000 | | | | | 30,000 | 30,000 | | 30,000 | 30,000 |
| | | | | | | | | | | | | | |

....ថ្ងៃទី.........ខែ........ឆ្នាំ២០១...

រៀបចំដោយ

## សហគមន៍កសិកម្ម.................

## សៀវភៅតាមដានសំណងឥណទាន

ឈ្មោះអ្នកខ្ចី៖................................... ភេទ.......... មុខរបរ............................................... នៅភូមិ.........................ឃុំ.............................ស្រុក.............................

| ល.រ | កាលបរិច្ឆេទ | | | ប្រាក់ខ្ចីដំបូង | រយៈពេលខ្ចី (ខែ) | អត្រាការប្រាក់ (ខែ) | ចំនួនការប្រាក់ត្រូវបង់(1)x(3)/100 | ចំនួនប្រាក់ដើមត្រូវបង់ | ចំនួនប្រាក់ត្រូវបង់ក្នុងមួយខែ | ប្រាក់ជំពាក់នៅសល់ |
|---|---|---|---|---|---|---|---|---|---|---|
| | ថ្ងៃ | ខែ | ឆ្នាំ | | | | | | | |
| | | | | ១ | ២ | ៣ | ៤ = ៧x៣/១០០ | 5= ៧/២ | ៦ = ៤+ ៥ | ៧ |
| 1 | 4 | កក្កដា | 2017 | 1,500,000 | 12 | 2.00 | 0 | 0 | 0 | 1,500,000 |
| 2 | 4 | សីហា | 2017 | | 11 | 2.00 | 30,000 | 0 | 30,000 | 1,500,000 |
| 3 | 4 | កញ្ញា | 2017 | | 10 | 2.00 | 30,000 | 0 | 30,000 | 1,500,000 |
| 4 | 4 | តុលា | 2017 | | 9 | 2.00 | 30,000 | 0 | 30,000 | 1,500,000 |
| 5 | 4 | វិច្ឆិកា | 2017 | | 8 | 2.00 | 30,000 | 0 | 30,000 | 1,500,000 |
| 6 | 4 | ធ្នូ | 2017 | | 7 | 2.00 | 30,000 | 0 | 30,000 | 1,500,000 |
| 7 | 4 | មករា | 2018 | | 6 | 2.00 | 30,000 | 0 | 30,000 | 1,500,000 |
| 8 | 4 | កុម្ភៈ | 2018 | | 5 | 2.00 | 30,000 | 0 | 30,000 | 1,500,000 |
| 9 | 4 | មីនា | 2018 | | 4 | 2.00 | 30,000 | 0 | 30,000 | 1,500,000 |
| 10 | 4 | មេសា | 2018 | | 3 | 2.00 | 30,000 | 0 | 30,000 | 1,500,000 |
| 11 | 4 | ឧសភា | 2018 | | 2 | 2.00 | 30,000 | 0 | 30,000 | 1,500,000 |
| 12 | 4 | មិថុនា | 2018 | | 1 | 2.00 | 30,000 | 0 | 30,000 | 1,500,000 |
| 13 | 4 | កក្កដា | 2018 | | 0 | 2.00 | 30,000 | 0 | 30,000 | 1,500,000 |

## សហគមន៍កសិកម្ម.................

## សៀវភៅតាមដានសំណងឥណទាន

ឈ្មោះអ្នកខ្ចី៖................................... ភេទ.......... មុខរបរ.............................................. នៅភូមិ.........................ឃុំ.............................ស្រុក.............................

| ល.រ | កាលបរិច្ឆេទ | | | ប្រាក់ខ្ចីដំបូង | រយៈពេលខ្ចី (ខែ) | អត្រាការប្រាក់ (ខែ) | ចំនួនការប្រាក់ត្រូវបង់(1)x(3)/100 | ចំនួនប្រាក់ដើមត្រូវបង់ | ចំនួនប្រាក់ត្រូវបង់ក្នុងមួយខែ | ប្រាក់ជំពាក់នៅសល់ |
|---|---|---|---|---|---|---|---|---|---|---|
| | ថ្ងៃ | ខែ | ឆ្នាំ | | | | | | | |
| | | | | ១ | ២ | ៣ | ៤ = ៧x៣/១០០ | 5= ៧/២ | ៦ = ៤+ ៥ | ៧ |
| 1 | 13 | មិថុនា | 2017 | 1,300,000 | 12 | 2.00 | 0 | | 0 | 1,300,000 |
| 2 | 13 | កក្កដា | 2017 | | 11 | 2.00 | 26,000 | 108,333.33 | 134,333 | 1,191,667 |
| 3 | 13 | សីហា | 2017 | | 10 | 2.00 | 23,833 | 108,333.33 | 132,167 | 1,083,333 |
| 4 | 13 | កញ្ញា | 2017 | | 9 | 2.00 | 21,667 | 108,333.33 | 130,000 | 975,000 |
| 5 | 13 | តុលា | 2017 | | 8 | 2.00 | 19,500 | 108,333.33 | 127,833 | 866,667 |
| 6 | 13 | វិច្ឆិកា | 2017 | | 7 | 2.00 | 17,333 | 108,333.33 | 125,667 | 758,333 |
| 7 | 13 | ធ្នូ | 2018 | | 6 | 2.00 | 15,167 | 108,333.33 | 123,500 | 650,000 |
| 8 | 13 | មករា | 2018 | | 5 | 2.00 | 13,000 | 108,333.33 | 121,333 | 541,667 |
| 9 | 13 | កុម្ភៈ | 2018 | | 4 | 2.00 | 10,833 | 108,333.33 | 119,167 | 433,333 |
| 10 | 13 | មីនា | 2018 | | 3 | 2.00 | 8,667 | 108,333.33 | 117,000 | 325,000 |
| 11 | 13 | មេសា | 2018 | | 2 | 2.00 | 6,500 | 108,333.33 | 114,833 | 216,667 |
| 12 | 13 | ឧសភា | 2018 | | 1 | 2.00 | 4,333 | 108,333.33 | 112,667 | 108,333 |
| 13 | 13 | មិថុនា | 2018 | | 0 | 2.00 | 2,167 | 108,333.33 | 110,500 | - |

**បញ្ជីតាមដានបំណុលអ្នកផ្គត់ផ្គង់ឬប្រាក់ត្រូវសង(ទិញទំនិញជឿ)៖** គឺជាបញ្ជីដែលកត់ត្រានូវរាល់ប្រតិបត្តិការទិញទំនិញគេជឿ ឬជំពាក់មិនទាន់បានបងប្រាក់រងចាំបង់នូវពេលក្រោយ។

**ចំណាំ៖** បញ្ជីនេះគេតែងតែស្រង់ចេញពីវិក័យបត្រ័ក្រុមហ៊ុនដែលទិញទំនិញគេជឿ។

## សហគមន៍កសិកម្ម……………………..

## បញ្ជីតាមដានបំណុលអ្នកផ្គត់ផ្គង់

| ល.រ | ឈ្មោះអ្នកផ្គត់ផ្គង់/ហាង | ប្រាក់នៅជំពាក់ | ប្រាក់បានសង | | | សមតុល្យ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | លើកទី១ | លើកទី២ | លើកទី៣ | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

. ថ្ងៃទី……ខែ……..ឆ្នាំ២០១…

អ្នកលក់

**បញ្ជីតាមដានបំណុលអតិថិជនប្រាក់ត្រូវទារ(លក់ទំនិញជឿ)៖** គឺជាបញ្ជីកត់ត្រានូវរាល់ប្រតិបត្តិការដែលសមាជិកសហគមន៍ទិញទំនិញពីសហគមន៍ជឿ និងរងចាំសងនូវពេលក្រោយ ឬសហគមន៍មិនទានបានទទួលប្រាក់។

**ចំណាំ៖** បញ្ជីនេះគេតែងតែស្រង់ចេញពីវិក័យបត្រលក់ទំនិញរបស់(AC)លក់ជឿ។

សហគមន៍កសិកម្ម................

## បញ្ជីតាមដានបំណុលអតិថិជន

| ល.រ | ឈ្មោះ អតិថិជន | ប្រាក់នៅជំពាក់ | ប្រាក់បានសង | | | សមតុល្យ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | លើកទី១ | លើកទី២ | លើកទី៣ | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

. ថ្ងៃទី......ខែ........ឆ្នាំ២០១...

អ្នកលក់

**បញ្ជីទំនិញក្នុងស្តុក, សាលាកប័ត្រឃ្លាំង(បញ្ជីទំនិញសល់ក្នុងឃ្លាំង)៖** បញ្ជីទំនិញក្នុងស្តុក ឬបញ្ជីទំនិញសល់ក្នុងឃ្លាំង ។ បញ្ជីនេះគេកត់ត្រានូវរាល់ទំនិញទាំងឡាយណាដែលលក់មិនអស់សល់ក្នុងឃ្លាំងហើយត្រូវការធ្វើការបិទបញ្ជីបំណាច់ខែ ឬបំណាច់ឆ្នាំដែលគេហៅថាធ្វើបញ្ជីសារពើ ភ័ណ្ឌ។

**ចំណាំ៖** រាល់បំណាច់ខែ, បំណាច់ឆ្នាំ ដែលត្រូវការរកប្រាក់ចំណេញគេតែងតែសរុបទំនិញសល់ក្នុងឃ្លាំងជាមុនសិនយកទៅចុះក្នុងសក្ខីប័ត្រចុះបញ្ជីដើម្បីវិភាគឥណពន្ធ, ឥណទានបញ្ចូលក្នុងតារាងរបាយការណ៍ហិរញ្ញវត្ថុ។

សហគមន៍កសិកម្ម

**សាលកប័ត្រឃ្លាំង(បញ្ជីស្តុកទំនិញ)** **ឈ្មោះ ទំនិញ**……………………………..

| កាលបរិច្ឆេទ | | កំណត់សំគាល់ | ទិញចូល | | | លក់ចេញ | | | សមតុល្យ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | បរិមាណ | ថ្លៃឯកតា | សរុប | បរិមាណ | ថ្លៃឯកតា | សរុប | បរិមាណ | ថ្លៃឯកតា | សរុប |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | សរុប ខែ……… | | | | | | | | | |
| | | ស្តុកផ្ទេរទៅខែក្រោយ | | | | | | | | | |
| | | ស្តុកសល់ផ្ទេរមកពីខែមុខ | | | | | | | | | |

. ថ្ងៃទី……ខែ……..ឆ្នាំ២០១…

អ្នកលក់

**សៀវភៅកុងធនាគារ(ប្រាក់ផ្ញើរធនាគារ)៖** សៀវភៅនេះសំរាប់កត់ត្រាប្រាក់របស់សហគមន៍ យកទៅដាក់ផ្ញើរធនគារ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុផ្សេងៗ។

### សៀវភៅកុងធនាគា (គណនីបញ្ញើសំចៃ)

| កាលបរិច្ឆេទ | លេខកូដ | ដាក់ប្រាក់ | ដកប្រាក់ | ថ្លៃប្រសិទ្ធភាព | សមតុល្យ | ហត្ថលេខា |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

# មេរៀនទី ៥ ជំហានសំខាន់ៗក្នុងការចុះបញ្ជីគណនេយ្យ

1. **ជំហានទី១ ៖ ប្រមូលផ្តុំឯកសារពាក់ព័ន្ធ**
2. **ជំហានទី២ ៖ វិភាគប្រតិបត្តិការ** ក្នុងករណីមានប្រតិបត្តិការកើតឡើងក្នុងគ្រា ចុះចូល **ទិន្នានុប្បវត្តិទូទៅ**តាមលំដាប់លំដោយ ជាមួយគ្នានេះដែរ ត្រូវស្រង់ទិន្នន័យដែលបានចុះក្នុងសៀវភៅទិនានុប្បវត្តិទូទៅចូល **គណនីសៀវភៅធំ ឬសៀវភៅមុខគណនី** ។ រៀងរាល់ចុងខែត្រូវបិទគណនីសៀវភៅធំនីមួយៗដើម្បីរកសមតុល្យចុងគ្រា សិន។
3. **ជំហានទី៣ ៖ ធ្វើតារាងតុល្យភាពសាកល្បងចុងគ្រា**
4. **ជំហានទី៤ ៖ ត្រួតពិនិត្យមើលចំណុចមួយចំនួនដែលត្រូវរៀបចំកែតម្រូវ**ដើម្បីបិទបញ្ជី និង **ធ្វើតារាងតុល្យភាពកែតម្រូវ**
5. **ជំហានទី៥ ៖ ធ្វើរបាយការណ៍ហិរញ្ញវត្ថុ (តារាងតុល្យការ និង របាយការណ៍លទ្ធផល ឬ ចំណេញខាត)**

តារាងរបាយការណ៍ហិរញ្ញវត្ថុ មាន តារាងតុល្យការ និងរបាយការណ៍លទ្ធផល(ខាត/ចំណេញ) គឺជាចម្លើយចុងក្រោយដែលអ្នកបិទបញ្ជីត្រូវធ្វើដើម្បីបង្ហាញពីដល់អ្នកពាក់ព័ន្ធទាំងឡាយណាដែលត្រូវការ រួមមាន៖ ប្រធានសហគមន៍កសិកម្ម គណៈកម្មាធិការត្រួតពិនិត្យ សមាជិក សវនករ មន្ទីរ ស្ថាប័នដៃគូ.........។

# លំហាត់អនុវត្ត ទី១

សហាគមន៍កសិកម្មបាត់ដំបង បានចុះបញ្ជីទទួលស្គាល់នៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១៧ និងទទួលបានសមាជិកចំនួន ៥០នាក់ ។ ប្រាក់សមាជិកទទួលបានចំនួន ៥០០,០០០រៀល និងលក់ហ៊ុនបានចំនួន ១០០ហ៊ុន ក្នុងតម្លៃមួយហ៊ុន ៥០,០០០រៀល ត្រូវជាប្រាក់ភាគហ៊ុនសរុបចំនួន ៥,០០០,០០០រៀល ។ ចាប់ពីថ្ងៃទី១០ ខែឧសភា រហូតដល់ថ្ងៃទី ៣១ ខែឧសភា គឺសហាគន៍មិនមានប្រតិបត្តិការអ្វីមួយកើតឡើងក្រៅពីប្រាក់សមាជិក និងប្រាក់ភាគហ៊ុនទេ ។ សូមធ្វើការចុះបញ្ជី និងបិទបញ្ជីគណនេយ្យចុងខែឧសភានេះ ។

__រំលឹកជំហាននៃការបិទបញ្ជី__

1. **ជំហានទី១ ៖ ប្រមូលផ្តុំឯកសារពាក់ព័ន្ធ**
2. **ជំហានទី២ ៖ វិភាគប្រតិបត្តិការ** ក្នុងករណីមានប្រតិបត្តិការកើតឡើងក្នុងគ្រា ចុះចូល**ទិន្នានុប្បវត្តិទូទៅ**តាមលំដាប់លំដោយ ជាមួយគ្នានេះដែរ ត្រូវស្រង់ទិន្នន័យដែលបានចុះក្នុងសៀវភៅទិនានុប្បវត្តិទូទៅចូលគណនី **សៀវភៅធំ ឬសៀវភៅមុខគណនី** ។ រៀងរាល់ចុងខែត្រូវបិទគណនីសៀវភៅធំនីមួយៗដើម្បីរកសមតុល្យចុងគ្រា សិន។
3. **ជំហានទី៣ ៖ ធ្វើតារាងតុល្យភាពសាកល្បងចុងគ្រា**
4. **ជំហានទី៤ ៖ ត្រួតពិនិត្យមើលចំណុចមួយចំនួនដែលត្រូវរៀបចំកែតម្រូវ** ដើម្បីបិទបញ្ជី និង ធ្វើតារាងតុល្យភាពកែតម្រូវ
5. **ជំហានទី៥ ៖ ធ្វើរបាយការណ៍ហិរញ្ញវត្ថុ (តារាងតុល្យការ និង របាយការណ៍លទ្ធផល ឬចំណេញខាត)**

## **ជំហានទី១៖ ការប្រមូលផ្តុំឯកសារ**

1. បញ្ជីបេឡាប្រចាំខែ(បញ្ជីសាច់ប្រាក់ចូលចេញ)
2. បញ្ជីតាមដានសំណងឥណទាន(របាយការណ៍ខ្ចីសង)
3. បញ្ជីតាមដានបំណុលអ្នកផ្គត់ផ្គង់(បញ្ជីជំពាក់បំណុលគេ)
4. បញ្ជីតាមដានបំណុលអតិថិជន(គេជំពាក់យើង)
5. សៀវភៅកុងធនាគា
6. បញ្ជីទំនិញក្នុងស្តុក(បញ្ជីទំនិញសល់ក្នុងឃ្លាំង)
7. បញ្ជីរំលស់អចលនៈទ្រព្យ
8. តារាងតុល្យការ និងរបាយការណ៍លទ្ធផលពីខែមុន
9. វិក័យបត្រចំណូល-ចំណាយផ្សេងៗ កិច្ចសន្យាខ្ចីសងជាដើម

**ជំហានទី២៖ វិភាគប្រតិបត្តិការ** ចុះចូល**ទិន្នានុប្បវត្តិទូទៅ**តាមលំដាប់លំដោយជាមួយគ្នានេះដែរ ត្រូវស្រង់ទិន្នន័យដែលបានចុះក្នុងសៀវភៅទិនានុប្បវត្តិទូទៅចូលគណនី **សៀវភៅធំ ឬសៀវភៅមុខគណនី** ។

> **ចំណាំ៖** រាល់ប្រតិបត្តិការអាជីវកម្មទាំងអស់ ចាំបាច់ត្រូវកត់ត្រាចូលក្នុងសៀវភៅ **ទិនានុប្បវត្តិទូទៅ** ដោយគោរពតាមវិធានឥណពន្ធ និងឥណទានខាងលើ។

## **សៀវភៅមុខគណនី ឬ សៀវភៅធំ**

សៀវភៅធំ គឺជាសៀវភៅដែលតាមដាននិងកត់ត្រារាល់ប្រតិបត្តិការរបស់រាល់មុខគណនីនីមួយៗដែលកើតឡើងពីប្រតិបត្តិការ និងមានសមតុល្យក្នុងពេលកំណត់មួយ ដោយចម្លងចេញពីទិនានុប្បវត្តិទូទៅ ។

> **ចំណាំ៖** ក្នុងឈ្មោះគណនីមួយ ត្រូវមានគណនីសៀវភៅធំមួយសម្រាប់កត់ត្រាមួយមុខៗទៅតាមប្រតិបត្តិការប្រចាំថ្ងៃ។ សូមបញ្ជាក់ថាប្រសិនបើមានឈ្មោះគណនីដូចគ្នាកើតឡើងដដែលៗ ប្រើតែគណនីសៀវភៅធំជាមួយគ្នា ចុះជាមួយគ្នារហូតដល់កាលកំណត់បិទការិយបរិច្ឆេទ រួចហើយត្រូវធ្វើការគណនារកសមតុល្យចុងគ្រាសម្រាប់ខែនីមួយៗ។

# ទិន្នានុប្បវត្តិទូទៅ

| កាលបរិច្ឆេទ | | ឈ្មោះគណនី និងបរិយាយ | ឥណពន្ធ | ឥណទាន |
|---|---|---|---|---|
| ខែ | ថ្ងៃទី | | | |
| ឧសភា | ១០ | សាច់ប្រាក់<br>ប្រាក់សមាជិកភាព<br>(សមាជិកបង់ប្រាក់សមាជិកភាព) | ៥០០,០០០ | <br>៥០០,០០០ |

## សៀវភៅមុខគណនី ឬ សៀវភៅធំ

**មុខគណនី៖...សាច់ប្រាក់.........** គិតត្រឹមថ្ងៃទី....៣១....ខែ.ឧសភា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មេសា | ៣០ | យោងសមតុល្យដើមគ្រា(សល់ពីខែមុន) | → | → | 0 |
| ឧសភា | ១០ | (សមាជិកបង់ប្រាក់សមាជិកភាព) | ៥០០,០០០ | | |

**មុខគណនី៖ ប្រាក់សមាជិកភាព** គិតត្រឹមថ្ងៃទី....៣១....ខែ.ឧសភា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មេសា | ៣០ | យោងសមតុល្យដើមគ្រា(សល់ពីខែមុន) | → | → | 0 |
| ឧសភា | ១០ | (សមាជិកបង់ប្រាក់សមាជិកភាព) | | ៥០០,០០០ | |

ដូច្នេះ សម្រាប់លំហាត់ទី១ យើងត្រូវចុះក្នុងជំហានទី២ ដូចខាងក្រោម៖

## ទិន្នានុប្បវត្តិទូទៅ

| កាលបរិច្ឆេទ | | ឈ្មោះគណនី និងបរិយាយ | ឥណពន្ធ | ឥណទាន |
|---|---|---|---|---|
| ខែ | ថ្ងៃទី | | | |
| ឧសភា | ១០ | សាច់ប្រាក់ | ៥០០,០០០ | |
| | | ប្រាក់សមាជិកភាព | | ៥០០,០០០ |
| | | (សមាជិកបង់ប្រាក់សមាជិកភាព) | | |
| ឧសភា | ១០ | សាច់ប្រាក់ | ៥,០០០,០០០ | |
| | | ប្រាក់ភាគហ៊ុន | | ៥,០០០,០០០ |
| | | (សមាជិកដាក់ហ៊ុនចូលសហគមន៍) | | |

តាមទិន្នានុប្បវត្តិទូទៅខាងលើ គឺ មាន ៣មុខគណនី ត្រូវចុះ ៣ សៀវភៅធំដែរ៖

| កាលបរិច្ឆេទ | | ឈ្មោះគណនី និងបរិយាយ | ឥណពន្ធ | ឥណទាន |
|---|---|---|---|---|
| ខែ | ថ្ងៃទី | | | |
| ឧសភា | ១០ | សាច់ប្រាក់ (មុខគណនីទី ១) | ...០,០០០ | |
| | | ប្រាក់សមាជិកភាព (មុខគណនីទី២) | | ៥០០,០០០ |
| | | (សមាជិកបង់ប្រាក់សមាជិកភាព) | | |
| ឧសភា | ១០ | សាច់ប្រាក់ (មុខគណនីទី ១) | ...០,០០០ | |
| | | ប្រាក់ភាគហ៊ុន (មុខគណនីទី៣) | | ៥,០០០,០០០ |
| | | (សមាជិកដាក់ហ៊ុនចូលសហគមន៍) | | |

**មុខគណនី៖...សាច់ប្រាក់.........** គិតត្រឹមថ្ងៃទី....៣១....ខែ.ឧសភា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មេសា | ៣០ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | | | ០ |
| ឧសភា | ១០ | (សមាជិកបង់ប្រាក់សមាជិកភាព) | ៥០០,០០០ | | |
| ឧសភា | ១០ | (សមាជិកដាក់ហ៊ុនចូលសហគមន៍) | ៥,០០០,០០០ | | |
| | | **សរុប** | **៥,៥០០,០០០** | ០ | **៥,៥០០,០០០** |

**មុខគណនី៖ ប្រាក់សមាជិកភាព** គិតត្រឹមថ្ងៃទី....៣១....ខែ.ឧសភា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មេសា | ៣០ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | → | → | ០ |
| ឧសភា | ១០ | (សមាជិកបង់ប្រាក់សមាជិកភាព) | | ៥០០,០០០ | |
| | | **សរុប** | **០** | **៥០០,០០០** | **៥០០,០០០** |

**មុខគណនី៖...ប្រាក់ភាគហ៊ុន...** គិតត្រឹមថ្ងៃទី....៣១....ខែ.ឧសភា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មេសា | ៣០ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | → | → | ០ |
| ឧសភា | ១០ | (សមាជិកដាក់ហ៊ុនចូលសហគមន៍) | | ៥,០០០,០០០ | |
| | | **សរុប** | **០** | **៥,០០០,០០០** | **៥,០០០,០០០** |

បើមានគណនីឈ្មោះផ្សេងៗត្រូវតែធ្វើដូចគ្នា ឲ្យបានគ្រប់ឈ្មោះគណនីនីមួយៗ ។

## ជំហានទី៣៖ ធ្វើតារាងតុល្យភាពសាកល្បងចុងគ្រា

តារាងតុល្យភាពសាកល្បងចុងគ្រា គឺត្រូវស្រង់ទិន្នន័យសមតុល្យចេញពីសៀវភៅធំ ឬ សៀវភៅមុខគណនីរបស់គណនីទាំងអស់ ដាក់តម្រៀបគ្នាបញ្ចូលក្នុងតារាងតែមួយ ដើម្បីពិនិត្យមើលថាតើវាមានភាពស្មើគ្នាឬទេ រវាងខាងឥណពន្ធ និងខាងឥណទាន?

តារាងតុល្យភាពសាកល្បងក្នុងលំហាត់ទី១

ត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

| ឈ្មោះគណនី | ឥណពន្ធ | ឥណទាន |
|---|---|---|
| ១. **ទ្រព្យសកម្ម** | | |
| - សាច់ប្រាក់ | ៛៥,៥00,000 | |
| ២. **បំណុល** | | |
| ៣. **ទុន** | | |
| - ប្រាក់សមាជិកភាព | | ៛៥00,000 |
| - ប្រាក់ភាគហ៊ុន | | ៛៥,000,000 |
| ៤. **ចំណូល** | | |
| ៥. **ចំណាយ** | | |
| សរុប | ៛៥,៥00,000 | ៛៥,៥00,000 |

ដោយសារក្នុងខែឧសភានេះ សហគមន៍កសិកម្ម មិនទាន់បានខ្ចីប្រាក់ពីអ្នកណាមួយឡើយ ហើយក៏មិនទាន់មានដំណើរការប្រកបមុខរបរជំនួញអ្វីដែរ ។ ដូច្នេះ ផ្នែកបំណុល ផ្នែកចំណូល និង ផ្នែកចំណាយមិនមានទេ ។

## ជំហានទី៤៖ ត្រួតពិនិត្យ និង ធ្វើតារាងតុល្យភាពកែតម្រូវ

ដោយសារតែក្នុងខែឧសភា សហគមន៍កសិកម្មមានតែ ២ប្រតិបត្តិការគឺ សមាជិកទិញហ៊ុន និងបង់ប្រាក់សមាជិកភាព ក្រៅពីនោះគឺគ្មានប្រតិបត្តិការណាផ្សេងកើតឡើងឡើយ ។ ដូច្នេះគឺមិនមានអ្វីដែលមានការខ្វះចន្លោះ ឬភ្លេចក្នុងការចុះក្នុងទិន្នានុប្បវត្តទូទៅទេ ។ គេធ្វើវានៅពេល ដែលមានប្រតិបត្តិការណាមួយ ឬ ច្រើន ខកខានមិនបានចុះក្នុងទិន្នានុប្បវត្តទូទៅ និងសៀវភៅធំ ដែលធ្វើនៅក្នុងជំហានទី ២ ជាដើម ។ ឧទាហរណ៍ដូចជា ប្រាក់មិនទាន់បានទទួលប្រាក់ត្រូវបង់ ការប្រាក់ត្រូវទារ និងប្រាក់កាត់រំលស់ឬទ្រព្យសកម្មរយៈពេលវែង។ ប៉ុន្តែយ៉ាងណាក៏ អ្នកចុះបញ្ជីត្រូវធ្វើការត្រួតពិនិត្យឲ្យបានប្រាកដថា រាល់ប្រតិបត្តិការរបស់សហគមន៍គឺត្រូវបានចុះក្នុងបញ្ជីត្រឹមត្រូវ និងរួចរាល់ហើយ ។

**ជាទូទៅ ប្រាក់កាត់រំលស់អចលទ្រព្យ គេច្រើនតែធ្វើការកាត់រំលស់នៅ ខែធ្នូចុងឆ្នាំ**

ដោយសារមិនមានចំណុចណាមួយត្រូវកែតម្រូវ ឬ ត្រូវបន្ថែម ដូច្នេះតារាងតុល្យភាពកែតម្រូវនេះគឺ គេអាចរំលងចោលបាន ពីព្រោះវានៅតែរក្សាតួលេខដដែល ។

**តារាងតុល្យភាពកែតម្រូវ**

| ឈ្មោះគណនី | តារាងតុល្យភាពសមតុល្យ | | ទិន្នានុប្បវត្តិកែតម្រូវដើម្បីបិទបញ្ជី | | សមតុល្យក្រោយកែតម្រូវ | |
|---|---|---|---|---|---|---|
| | ឥណពន្ធ | ឥណទាន | ឥណពន្ធ | ឥណទាន | ឥណពន្ធ | ឥណទាន |
| ១. ទ្រព្យសកម្ម | | | | | | |
| សាច់ប្រាក់ | ៛៥,៥00,000 | | | | ៛៥,៥00,000 | |
| ២. បំណុល | | | | | | |
| ៣. ទុន | | | | | | |
| ប្រាក់សមាជិកភាព | | ៛៥00,000 | | | | ៛៥00,000 |
| ប្រាក់ភាគហ៊ុន | | ៛៥,000,000 | | | | ៛៥,000,000 |
| ៤. ចំណូល | | | | | | |
| ៥. ចំណាយ | | | | | | |
| សរុប | ៛៥,៥00,000 | ៛៥,៥00,000 | 0 | 0 | ៛៥,៥00,000 | ៛៥,៥00,000 |

## ជំហានទី៥៖ តារាងរបាយការណ៍ហិរញ្ញវត្ថុ

1. **តារាងតុល្យការ៖** ជាតារាងដែលបង្ហាញនូវទ្រព្យសកម្ម បំណុល និងទុន ដោយមានរូបមន្ត

**ទ្រព្យសកម្ម = បំណុល + ទុន**

ឬ មានទម្រង់

| ទ្រព្យសកម្ម | បំណុល |
|---|---|
| | ទុន |

2. **តារាងរបាយការណ៍លទ្ធផល** = របាយការណ៍ចំណេញ/ខាត ៖ បង្ហាញពីផល ចំណេញ ឬ ខាតនៃប្រតិបត្តិការអាជីវកម្មក្នុងរយៈពេលមួយកំណត់ ។

**ចំណេញ/ខាត = ចំណូលសរុប - ចំណាយសរុប**

ចំពោះលំហាត់ទី១នេះ៖

តារាងតុល្យការ

ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៧

| | | | |
|---|---|---|---|
| **១. ទ្រព្យសកម្ម** | សមតុល្យ | **២. បំណុល** | សមតុល្យ |
| - សាច់ប្រាក់ | ៥,៥០០,០០០ | | |
| | | **៣. ទុន** | |
| | | - ប្រាក់ភាគហ៊ុន | ៥,០០០,០០០ |
| | | - ប្រាក់សមាជិកភាព | ៥០០,០០០ |
| **សរុប** | **៥,៥០០,០០០** | **សរុប= ២+៣** | **៥,៥០០,០០០** |

ចំណែករបាយការណ៍លទ្ធផលមិនមានទេសម្រាប់ខែ ឧសភា ឆ្នាំ២០១៧នេះ ដោយសារសហគមន៍កសិកម្មមិនទាន់បានវិនិយោគក្នុងមុខរបរណាមួយឡើយ ។

ដូច្នេះការបិទបញ្ជីសម្រាប់ខែឧសភានេះ គឺមានត្រឹមតែតារាងតុល្យការ ។

# លំហាត់អនុវត្ត ទី២

នៅក្នុងខែមិថុនា ឆ្នាំ២០១៧ សហគមន៍កសិកម្ម បាត់ដំបង មានប្រតិបត្តិការជាច្រើន៖

- ០២/០៦/១៧៖ អាជ្ញាធរឃុំបានផ្តល់ដីទំហំ ១ហិកតាដល់សហគមន៍ ។ តាមការវាយតម្លៃដីនោះមានតម្លៃប្រហែល ២០,០០០,០០០រៀល ។
- ០៤/០៦/១៧៖ សហគមន៍ បានទៅខ្ចីប្រាក់ពីធនាគារចំនួន ២០,០០០,០០០រៀល ក្នុងការប្រាក់ ១.៥%ក្នុងមួយឆ្នាំ
- ១១/០៦/១៧៖ សហគមន៍បានផ្តល់ប្រាក់ចំនួន ៣,២០០,០០០រៀល ដល់សមាជិកឈ្មោះ សុខ នី ខ្ចីក្នុងអត្រាការប្រាក់ ២%ក្នុងមួយខែ ។
- ១៣/០៦/១៧៖ សហគមន៍បានផ្តល់ប្រាក់ចំនួន ១,៣០០,០០០រៀល ដល់សមាជិកឈ្មោះ សៅ សុខា ក្នុងអត្រាការប្រាក់ ២%ក្នុងមួយខែ ។
- ២១/០៦/១៧៖ សហគមន៍បានយកប្រាក់ចំនួន ១៦,០០០,០០០រៀល ទៅផ្ញើក្នុងធនាគារ
- ២៩/០៦/១៧៖ សហគមន៍បានចំណាយអស់ប្រាក់ ៤០,០០០រៀល សម្រាប់ប្រជុំប្រចាំខែ ។

ចូរធ្វើការចុះបញ្ជី និង បិទបញ្ជីគណនេយ្យសម្រាប់ខែមិថុនា ឆ្នាំ២០១៧ ?

## ជំហានទី១៖ ការប្រមូលផ្តុំឯកសារ

- បញ្ជីបេឡា(បញ្ជីសាច់ប្រាក់ចូលចេញ)
- បញ្ជីតាមដានសំណងឥណទាន(របាការណ៍ខ្ចីសង)
- បញ្ជីតាមដានបំណុលអ្នកផ្គត់ផ្គង់(បញ្ជីជំពាក់បំណុលគេ)
- បញ្ជីតាមដានបំណុលអតិថិជន(គេជំពាក់យើង)
- សៀវភៅកុងធនាគា
- បញ្ជីទំនិញក្នុងស្តុក(បញ្ជីទំនិញសល់ក្នុងឃ្លាំង)
- បញ្ជីវលស់អចលនៈទ្រព្យ
- តារាងតុល្យភាពសាកល្បងទូទាត់ពីខែមុន ឬ តារាងតុល្យការ និងរបាយការណ៍លទ្ធផលពីខែមុន

➢ តារាងតុល្យការខែឧសភា

| **១. ទ្រព្យសកម្ម** | សមតុល្យ | **២. បំណុល** | សមតុល្យ |
|---|---|---|---|
| - សាច់ប្រាក់ | ៥,៥០០,០០០ | | |
| | | **៣. ទុន** | |
| | | - ប្រាក់ភាគហ៊ុន | ៥,០០០,០០០ |
| | | - ប្រាក់សមាជិកភាព | ៥០០,០០០ |
| **សរុប** | **៥,៥០០,០០០** | **សរុប = ២+ ៣** | **៥,៥០០,០០០** |

**ជំហានទី២៖** **វិភាគប្រតិបត្តិការ** ចុះចូល**ទិន្នានុប្បវត្តិទូទៅ**តាមលំដាប់លំដោយជាមួយគ្នានេះដែរ ត្រូវស្រង់ទិន្នន័យដែលបានចុះក្នុងសៀវភៅទិនានុប្បវត្តិទូទៅចូលគណនី **សៀវភៅធំ ឬសៀវភៅមុខគណនី** ។

## ទិន្នានុប្បវត្តិទូទៅ

| កាលបរិច្ឆេទ | | ឈ្មោះគណនី និងបរិយាយ | ឥណពន្ធ | ឥណទាន |
|---|---|---|---|---|
| ខែ | ថ្ងៃទី | | | |
| មិថុនា | ០២ | ដី<br>អំណោយឃុំ<br>(ឃុំផ្តល់ដីឲ្យសហគមន៍១ហិចតា) | ២០,០០០,០០០ | ២០,០០០,០០០ |
| មិថុនា | ០៤ | សាច់ប្រាក់<br>ប្រាក់ខ្ចីធនាគារ<br>(ខ្ចីប្រាក់ពីធនាគារ) | ២០,០០០,០០០ | ២០,០០០,០០០ |
| មិថុនា | ១១ | ប្រាក់ឲ្យខ្ចី<br>សាច់ប្រាក់<br>(ឲ្យសុខ នី ខ្ចីប្រាក់) | ៣,២០០,០០០ | ៣,២០០,០០០ |
| មិថុនា | ១៣ | ប្រាក់ឲ្យខ្ចី<br>សាច់ប្រាក់<br>(ឲ្យសៅ សុខា ខ្ចីប្រាក់) | ១,៣០០,០០០ | ១,៣០០,០០០ |
| មិថុនា | ២១ | ប្រាក់ផ្ញើធនាគារ<br>សាច់ប្រាក់<br>(ដាក់ប្រាក់ផ្ញើធនាគារ) | ១៦,០០០,០០០ | ១៦,០០០,០០០ |

| | | | | |
|---|---|---|---|---|
| មិថុនា | ២៩ | ចំណាយប្រជុំ<br>សាច់ប្រាក់<br>(ប្រជុំប្រចាំខែមិថុនា) | ៤០,០០០ | ៤០,០០០ |

## សៀវភៅមុខគណនី ឬសៀវភៅធំ

(សមតុល្យចុងគ្រាខែឧសភា = សមតុល្យដើមគ្រាខែមិថុនា)

**មុខគណនី៖...សាច់ប្រាក់.........** គិតត្រឹមថ្ងៃទី....៣០....ខែ...មិថុនា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| ឧសភា | ៣១ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | → | → | **៥,៥០០,០០០** |
| មិថុនា | ០៤ | (ខ្ចីប្រាក់ពីធនាគារ) | ២០,០០០,០០០ | | ២៥,៥០០,០០០ |
| មិថុនា | ១១ | (ឲ្យសុខ នី ខ្ចីប្រាក់) | | ៣,២០០,០០០ | ២២,៣០០,០០០ |
| មិថុនា | ១៣ | (ឲ្យសៅ សុខា ខ្ចីប្រាក់) | | ១,៣០០,០០០ | ២១,០០០,០០០ |
| មិថុនា | ២១ | (ដាក់ប្រាក់ផ្ញើធនាគារ) | | ១៦,០០០,០០០ | ៥,០០០,០០០ |
| មិថុនា | ២៩ | (ចំណាយប្រជុំខែមិថុនា) | | ៤០,០០០ | ៤,៩៦០,០០០ |
| | | សរុប | **២០,០០០,០០០** | **២០,៥៤០,០០០** | **៤,៩៦០,០០០** |

**មុខគណនី៖...ដីសហគមន៍....** គិតត្រឹមថ្ងៃទី....៣០....ខែ.មិថុនា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| ឧសភា | ៣១ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | → | → | 0 |
| មិថុនា | ០២ | (ឃុំផ្តល់ដីឲ្យសហគមន៍១ហិចតា) | ២០,០០០,០០០ | | ២០,០០០,០០០ |
| | | សរុប | **២០,០០០,០០០** | | **២០,០០០,០០០** |

**មុខគណនី៖...អំណោយរដ្ឋ....** គិតត្រឹមថ្ងៃទី....៣០....ខែ.មិថុនា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| ឧសភា | ៣១ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | → | → | 0 |
| មិថុនា | ០២ | (ឃុំផ្តល់ដីឲ្យសហគមន៍១ហិចតា) | | ២0,000,000 | ២0,000,000 |
| | | សរុប | | **២0,000,000** | **២0,000,000** |

**មុខគណនី៖...ប្រាក់ខ្ចីធនាគារ....** គិតត្រឹមថ្ងៃទី....៣០....ខែ.មិថុនា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| ឧសភា | ៣១ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | → | → | 0 |
| មិថុនា | ០៤ | (ខ្ចីប្រាក់ពីធនាគារ) | | ២0,000,000 | ២0,000,000 |
| | | សរុប | 0 | **២0,000,000** | **២0,000,000** |

**មុខគណនី៖...ប្រាក់ឲ្យគេខ្ចី....** គិតត្រឹមថ្ងៃទី....៣០....ខែ.មិថុនា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| ឧសភា | ៣១ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | → | → | 0 |
| មិថុនា | ១១ | (ឲ្យសុខ នី ខ្ចីប្រាក់) | ៣,២00,000 | | |
| មិថុនា | ១៣ | (ឲ្យសៅ សុខា ខ្ចីប្រាក់) | ១,៣00,000 | | |
| | | សរុប | **៤,៥00,000** | 0 | **៤,៥00,000** |

**មុខគណនី៖...ប្រាក់ផ្ញើធនាគារ...** គិតត្រឹមថ្ងៃទី....៣០....ខែ.មិថុនា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| ឧសភា | ៣១ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | → | → | 0 |
| មិថុនា | ២១ | (ដាក់ប្រាក់ផ្ញើធនាគារ) | ១៦,000,000 | | |
| | | សរុប | **១៦,000,000** | 0 | **១៦,000,000** |

**មុខគណនី៖...ចំណាយប្រជុំ...** គិតត្រឹមថ្ងៃទី....៣០....ខែ.មិថុនា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| ឧសភា | ៣១ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | → | → | 0 |
| មិថុនា | ២៩ | (ចំណាយប្រជុំខែមិថុនា) | ៤០,០០០ | | |
| | | សរុប | **៤០,០០០** | **0** | **៤០,០០០** |

## ជំហានទី៣៖ ធ្វើតារាងតុល្យភាពសាកល្បងចុងគ្រា

(ត្រូវស្រង់ទិន្នន័យសមតុល្យចេញពីសៀវភៅធំ ឬសៀវភៅមុខគណនី )

តារាងតុល្យភាពសាកល្បងក្នុងលំហាត់ទី២

ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

| ឈ្មោះគណនី | ឥណពន្ធ | ឥណទាន |
|---|---|---|
| **១. ទ្រព្យសកម្ម** | | |
| - សាច់ប្រាក់ | 4,960,000 | |
| - ប្រាក់ផ្ញើធនាគារ | 16,000,000 | |
| - ប្រាក់ឲ្យគេខ្ចី | 4,500,000 | |
| - ដី | 20,000,000 | |
| **២. បំណុល** | | |
| - ប្រាក់ខ្ចីធនាគារ | | 20,000,000 |
| **៣. ទុន** | | |
| - ប្រាក់សមាជិកភាព | | 500,000 |
| - ប្រាក់ភាគហ៊ុន | | 5,000,000 |
| - អំណោយវេជ្ជ | | 20,000,000 |
| **៤. ចំណូល** | | |
| **៥. ចំណាយ** | | |
| - ចំណាយប្រជុំ | 40,000 | |
| សរុប | 45,500,000 | 45,500,000 |

ឬ

| | | | |
|---|---|---|---|
| **១. ទ្រព្យសកម្ម** | សមតុល្យ | **២. បំណុល** | សមតុល្យ |
| **ទ្រព្យសកម្មចល័ត (១)** | | - ប្រាក់ខ្ចីធនាគារ | ២០,០០០,០០០ |
| - សាច់ប្រាក់ | ៤,៩៦០,០០០ | | |
| - ប្រាក់ផ្ញើធនាគារ | ១៦,០០០,០០០ | **៣. ទុន** | |
| - ប្រាក់ឲ្យគេខ្ចី | ៤,៥០០,០០០ | - ប្រាក់ភាគហ៊ុន | ៥,០០០,០០០ |
| **ទ្រព្យសកម្មអចល័ត (២)** | | - ប្រាក់សមាជិកភាព | ៥០០,០០០ |
| - ដី | ២០,០០០,០០០ | - អំណោយរដ្ឋ(ដី) | ២០,០០០,០០០ |
| **៤. ចំណាយ** | | **៥. ចំណូល** | |
| - **ចំណាយរដ្ឋបាល** | ៤០,០០០ | | |
| **សរុប** | **៤៥,៥០០,០០០** | **សរុប** | **៤៥,៥០០,០០០** |

## ជំហានទី៤៖ ត្រួតពិនិត្យ និងធ្វើតារាងតុល្យភាពកែតម្រូវ

ជំហាននេះ គឺត្រូវរកមើលប្រតិបត្តិការណាដែលមិនទាន់បានចុះបញ្ជីដើម្បីធ្វើការចុះបញ្ជីក្នុងទិន្នានុប្បវត្តទូទៅ និងធ្វើការកែតម្រូវក្នុងតារាងតុល្យភាពកែតម្រូវបន្ត ។

ចំណុចដែលត្រូវពិចារណាក្នុងការត្រួតពិនិត្យសម្រាប់ធ្វើការបិទបញ្ជីរួមមាន៖

1. ការប្រាក់នៃប្រាក់ផ្ញើធនាគារដែលមិនទាន់បានទទួល ៖ ដោយសហគមន៍យកប្រាក់ទៅដាក់ធនាគារនៅថ្ងៃទី ២១ ដូច្នេះគឺមិនទាន់បានការប្រាក់ទេ ត្រូវរង់ចាំនៅខែកក្កដា
2. ការប្រាក់នៃប្រាក់ឲ្យគេខ្ចីដែលត្រូវទារ ៖ មិនទាន់ដល់ថ្ងៃទទួលទេ ត្រូវរង់ចាំខែក្រោយ ដោយសារសហគមន៍ផ្តល់ឲ្យគេនៅថ្ងៃទី ១១ខែមិថុនា
3. ការប្រាក់នៃប្រាក់កម្ចីដែលត្រូវបង់ ៖ សហគមន៍បានខ្ចីប្រាក់ធនាគារនៅថ្ងៃទី ០៤ ដូច្នេះត្រូវបង់ការប្រាក់ និងប្រាក់ដើមនៅថ្ងៃទី ០៤ ខែកក្កដា វិញ
4. ការរំលស់អចលនៈទ្រព្យ ៖ ភាគច្រើនគេធ្វើឡើងនៅចុងឆ្នាំរៀងរាល់ខែធ្នូ គឺមួយឆ្នាំធ្វើការកាត់រំលស់ម្តង
5. ឬមួយប្រតិបត្តិការណាមួយដែលបានភ្លេចក្នុងការចុះបញ្ជីក្នុងសក្ខីបត្រ....។

ដោយសារមិនមានចំណុចណាមួយត្រូវកែតម្រូវ ឬ ត្រូវបន្ថែម ដូច្នេះតារាងតុល្យភាពកែតម្រូវនេះគឺ គេអាចរំលងចោលបាន ពីព្រោះវានៅតែរក្សាតួលេខដដែល ។

## តារាងតុល្យភាពកែតម្រូវ

| ឈ្មោះគណនី | តារាងតុល្យភាពសមតុល្យ | | ទិន្នានុប្បវត្តិកែតម្រូវដើម្បីបិទបញ្ជី | | សមតុល្យក្រោយកែតម្រូវ | |
|---|---|---|---|---|---|---|
| | ឥណពន្ធ | ឥណទាន | ឥណពន្ធ | ឥណទាន | ឥណពន្ធ | ឥណទាន |
| សាច់ប្រាក់ | 4,960,000 | | | | 4,960,000 | |
| ប្រាក់ផ្ញើធនាគារ | 16,000,000 | | | | 16,000,000 | |
| ប្រាក់ឲ្យគេខ្ចី | 4,500,000 | | | | 4,500,000 | |
| ដី | 20,000,000 | | | | | |
| ប្រាក់ខ្ចីធនាគារ | | 20,000,000 | | | | 20,000,000 |
| ប្រាក់សមាជិក | | 500,000 | | | | 500,000 |
| ប្រាក់ភាគហ៊ុន | | 5,000,000 | | | | 5,000,000 |
| អំណោយរដ្ឋ | | 20,000,000 | | | | 20,000,000 |
| ចំណូល | | | | | | |
| ចំណាយប្រជុំ | 40,000 | | | | 40,000 | |
| សរុប | **45,500,000** | **45,500,000** | | | **45,500,000** | **45,500,000** |

## ជំហានទី៥៖ តារាងរបាយការណ៍ហិរញ្ញវត្ថុ
## តារាងតុល្យការ
## ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

| ១. ទ្រព្យសកម្ម | សមតុល្យ | ២. បំណុល | សមតុល្យ |
|---|---|---|---|
| **ទ្រព្យសកម្មចល័ត (១)** | | - ប្រាក់ខ្ចីធនាគារ | 20,000,000 |
| - សាច់ប្រាក់ | 4,960,000 | | |
| - ប្រាក់ផ្ញើធនាគារ | 16,000,000 | **៣. ទុន** | |
| - ប្រាក់ឲ្យគេខ្ចី | 4,500,000 | - ប្រាក់សមាជិកភាព | 500,000 |
| **ទ្រព្យសកម្មអចល័ត (២)** | | - ប្រាក់ភាគហ៊ុន | 5,000,000 |
| - ដី | 20,000,000 | - អំណោយរដ្ឋ(ដី) | 20,000,000 |
| | | - ខាត | ( ) 40,000 |
| សរុប | 45,460,000 | **សរុប** | 45,460,000 |

**របាយការណ៍លទ្ធផល= របាយការណ៍ចំណេញ/ខាត**

ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

| | | |
|---|---|---|
| **ខាត/ចំណេញខែមុខ (ឧសភា)** | | 0 |
| **ចំណូលខែមិថុនា** | | 0 |
| **ចំណាយខែមិថុនា** | | |
| ចំណាយប្រជុំប្រចាំខែ | 40,000 | |
| សរុបចំណាយ | 40,000 | |
| **ខាត/ចំណេញសុទ្ធ** | | ( ) 40,000 |

# លំហាត់អនុវត្តទី ៣

ក្នុងខែកក្កដា ឆ្នាំ២០១៧ សហគមន៍កសិកម្មបាត់ដំបង មានប្រតិបត្តិការដូចខាងក្រោម៖

- ០៣/០៧/១៧៖ សហគមន៍បង់សងប្រាក់ដើមចំនួន ១,៦៦៧,០០០រៀល និងបង់ការប្រាក់ចំនួន ៣០០,០០០រៀល ដោយទូទាត់តាមធនាគារ
- ០៤/០៧/១៧៖ សហគមន៍កសិកម្មបានទទួលសមាជិកចំនួន ១២នាក់បន្ថែម ដោយទទួលបានប្រាក់សមាជិកភាព ១២០,០០០រៀល និង ប្រាក់ភាគហ៊ុន ៨០០,០០០រៀល
- ០៧/០៧/១៧៖ មីងរី បានខ្ចីប្រាក់ ២,០០០,០០០រៀល ក្នុងមួយខែការប្រាក់ ២%
- ១៣/០៧/១៧៖ ទទួលបានការប្រាក់ចំនួន ៦៤,០០០រៀល ពីពូ សុខនី
- ១៥/០៧/១៧៖ ពូសាក់បានខ្ចីប្រាក់ចំនួន ២,៥០០,០០០រៀល ការប្រាក់ ២%ក្នុង១ខែ
- ២១/០៧/១៧៖ សហគមន៍បានដកប្រាក់ចំនួន ១០,០០០,០០០រៀលពីធនាគារ
- ២២/០៧/១៧៖ សហគមន៍បានចំណាយប្រាក់អស់ ៨,៤០០,០០០រៀល ក្នុងការសាងសង់ទីស្នាក់ការសហគមន៍ទុកសម្រាប់ប្រជុំ
- ២៧/០៧/១៧៖ សមាជិក៣០នាក់បានដាក់ប្រាក់សន្សំចំនួន ៦០០,០០០
- ២៩/០៧/១៧៖ សហគមន៍ចំណាយអស់ ៣៨,០០០រៀលសម្រាប់ប្រជុំប្រចាំខែ

ចូរធ្វើការបិទបញ្ជីសម្រាប់ខែកក្កដា ?

## ជំហានទី១៖ ការប្រមូលផ្តុំឯកសារ

- បញ្ជីបេឡា(បញ្ជីសាច់ប្រាក់ចូលចេញ)
- បញ្ជីតាមដានសំណងឥណទាន(របាការណ៍ខ្ចីសង)
- បញ្ជីតាមដានបំណុលអ្នកផ្គត់ផ្គង់(បញ្ជីជំពាក់បំណុលគេ)
- បញ្ជីតាមដានបំណុលអតិថិជន(គេជំពាក់យើង)
- សៀវភៅកុងធនាគា
- បញ្ជីទំនិញក្នុងស្តុក(បញ្ជីទំនិញសល់ក្នុងឃ្លាំង)
- បញ្ជីវលស់អចលនៈទ្រព្យ
- តារាងតុល្យការពីខែមុន (មិថុនា)

តារាងតុល្យការ ខែមិថុនា

| **១. ទ្រព្យសកម្ម** | សមតុល្យ | **២. បំណុល** | សមតុល្យ |
|---|---|---|---|
| **ទ្រព្យសកម្មចល័ត (១)** | | - ប្រាក់ខ្ចីធនាគារ | 20,000,000 |
| - សាច់ប្រាក់ | 4,960,000 | | |
| - ប្រាក់ផ្ញើធនាគារ | 16,000,000 | **៣. ទុន** | |
| - ប្រាក់ឲ្យគេខ្ចី | 4,500,000 | - ប្រាក់សមាជិកភាព | 500,000 |
| **ទ្រព្យសកម្មអចល័ត (២)** | | - ប្រាក់ភាគហ៊ុន | 5,000,000 |
| - ដី | 20,000,000 | - អំណោយរដ្ឋ(ដី) | 20,000,000 |
| | | - ខាត | (-) 40,000 |
| សរុប | 45,460,000 | **សរុប** | 45,460,000 |

**ជំហានទី២៖ វិភាគប្រតិបត្តិការ** ចុះចូល**ទិន្នានុប្បវត្តិទូទៅ**តាមលំដាប់លំដោយជាមួយគ្នានេះដែរ ត្រូវស្រង់ទិន្នន័យដែលបានចុះក្នុងសៀវភៅទិនានុប្បវត្តិទូទៅចូលគណនី **សៀវភៅធំ ឬសៀវភៅមុខគណនី** ។

## ទិន្នានុប្បវត្តិទូទៅ

| កាលបរិច្ឆេទ | | ឈ្មោះគណនី និងបរិយាយ | ឥណពន្ធ | ឥណទាន |
|---|---|---|---|---|
| ខែ | ថ្ងៃទី | | | |
| កក្កដា | ៣ | ប្រាក់ខ្ចីធនាគារ<br>ចំណាយការប្រាក់<br>ប្រាក់ផ្ញើធនាគារ<br>(សងប្រាក់ខ្ចីធនាគារ និងបង់ការប្រាក់) | ១,៦៦៧,០០០<br>៣០០,០០០ | <br><br>១,៩៦៧,០០០ |
| កក្កដា | ៤ | សាច់ប្រាក់<br>ប្រាក់សមាជិកភាព<br>ប្រាក់ភាគហ៊ុន<br>(បញ្ចូលសមាជិកថ្មីក្នុងសហគមន៍) | ៩២០,០០០ | <br>១២០,០០០<br>៨០០,០០០ |
| កក្កដា | ៧ | ប្រាក់ឲ្យគេខ្ចី<br>សាច់ប្រាក់<br>(មីងរីខ្ចីប្រាក់ពីសហគមន៍) | ២,០០០,០០០ | <br>២,០០០,០០០ |

| | | | | |
|---|---|---|---|---|
| កក្កដា | ១៣ | សាច់ប្រាក់<br>ចំណូលការប្រាក់<br>(ទទួលបានការប្រាក់ពីពូ សុខនី) | ៦៤,០០០ | ៦៤,០០០ |
| កក្កដា | ១៥ | ប្រាក់ឲ្យគេខ្ចី<br>សាច់ប្រាក់<br>(ពូសាក់ខ្ចីប្រាក់សហគមន៍) | ២,៥០០,០០០ | ២,៥០០,០០០ |
| កក្កដា | ២១ | សាច់ប្រាក់<br>ប្រាក់ផ្ញើធនាគារ<br>(ដកប្រាក់ពីធនាគារ) | ១០,០០០,០០០ | ១០,០០០,០០០ |
| កក្កដា | ២២ | ទីស្នាក់ការ<br>សាច់ប្រាក់<br>(សាងសង់ទីស្នាក់ការសហគមន៍) | ៨,៤០០,០០០ | ៨,៤០០,០០០ |
| កក្កដា | ២២ | សាច់ប្រាក់<br>ប្រាក់សន្សំសមាជិក<br>(សមាជិកដាក់ប្រាក់សន្សំ) | ៦០០,០០០ | ៦០០,០០០ |
| កក្កដា | ២៩ | ចំណាយប្រជុំ<br>សាច់ប្រាក់<br>(ចំណាយប្រជុំប្រចាំខែកក្កដា) | ៣៨,០០០ | ៣៨,០០០ |

## សៀវភៅមុខគណនី ឬសៀវភៅធំ

**មុខគណនីៈ...ប្រាក់ខ្ចីធនាគារ...** គិតត្រឹមថ្ងៃទី....៣១....ខែ.កក្កដា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មិថុនា | ៣០ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | | | **២០,០០០,០០០** |
| កក្កដា | ៣ | (សងប្រាក់ខ្ចីធនាគារ) | ១,៦៦៧,០០០ | | |
| | | **សរុប** | **១,៦៦៧,០០០** | **០** | **១៨,៣៣៣,០០០** |

**មុខគណនីៈ...ប្រាក់ផ្ញើធនាគារ...** គិតត្រឹមថ្ងៃទី....៣១....ខែ.កក្កដា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មិថុនា | ៣០ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | → | → | **១៦,000,000** |
| កក្កដា | ៣ | (សងប្រាក់ខ្ចីធនាគារ) | | ១,៦៦៧,000 | |
| កក្កដា | ៣ | (បង់ការប្រាក់ធនាគារ) | | ៣00,000 | |
| កក្កដា | ២១ | (ដកប្រាក់ពីធនាគារ) | | ១0,000,000 | |
| | | **សរុប** | **0** | **១១,៩៦៧,000** | **៤,0៣៣,000** |

**មុខគណនីៈ...ចំណាយការប្រាក់** គិតត្រឹមថ្ងៃទី....៣១....ខែ.កក្កដា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មិថុនា | ៣០ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | → | → | **0** |
| កក្កដា | ៣ | (បង់ការប្រាក់ធនាគារ) | ៣00,000 | | |
| | | **សរុប** | **៣00,000** | **0** | **៣00,000** |

**មុខគណនីៈ...ប្រាក់សមាជិកភាព** គិតត្រឹមថ្ងៃទី....៣១....ខែ.កក្កដា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មិថុនា | ៣០ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | → | → | **៥00,000** |
| កក្កដា | ៤ | ទទួលបានប្រាក់សមាជិកភាព | | ១២0,000 | |
| | | **សរុប** | **0** | **១២0,000** | **៦២0,000** |

**មុខគណនី៖...ប្រាក់ភាគហ៊ុន** គិតត្រឹមថ្ងៃទី....៣១....ខែ.កក្កដា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មិថុនា | ៣០ | យោងសមតុល្យដើមគ្រា(សល់ពីខែមុន) | → | → | ៥,000,000 |
| កក្កដា | ៤ | ទទួលបានប្រាក់ភាគហ៊ុន | | ៨00,000 | |
| | | សរុប | 0 | ៨00,000 | ៥,៨00,000 |

**មុខគណនី៖...ប្រាក់ឲ្យគេខ្ចី** គិតត្រឹមថ្ងៃទី....៣១....ខែ.កក្កដា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មិថុនា | ៣០ | យោងសមតុល្យដើមគ្រា(សល់ពីខែមុន) | → | → | ៤,៥00,000 |
| កក្កដា | ៧ | (មីងរីខ្ចីប្រាក់ពីសហគមន៍) | ២,000,000 | | |
| កក្កដា | ១៥ | (ពូសាក់ខ្ចីប្រាក់សហគមន៍) | ២,៥00,000 | | |
| | | សរុប | ៤,៥00,000 | 0 | ៩,000,000 |

**មុខគណនី៖...ចំណូលការប្រាក់** គិតត្រឹមថ្ងៃទី....៣១....ខែ.កក្កដា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មិថុនា | ៣០ | យោងសមតុល្យដើមគ្រា(សល់ពីខែមុន) | → | → | 0 |
| កក្កដា | ១៣ | (ទទួលបានការប្រាក់ពីពូ សុខនី) | | ៦៤,000 | |
| | | សរុប | 0 | ៦៤,000 | ៦៤,000 |

**មុខគណនី៖...អាគារទីស្នាក់ការ** គិតត្រឹមថ្ងៃទី....៣១....ខែ.កក្កដា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មិថុនា | ៣០ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | | | 0 |
| កក្កដា | ២២ | (សាងសង់ទីស្នាក់ការសហគមន៍) | ៨,៤០០,០០០ | | |
| | | **សរុប** | **៨,៤០០,០០០** | **0** | **៨,៤០០,០០០** |

**មុខគណនី៖...ប្រាក់សន្សំសមាជិក** គិតត្រឹមថ្ងៃទី....៣១....ខែ.កក្កដា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មិថុនា | ៣០ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | | | 0 |
| កក្កដា | ២៧ | (សមាជិកបានដាក់ប្រាក់សន្សំ) | | ៦០០,០០០ | |
| | | **សរុប** | **0** | ៦០០,០០០ | **៦០០,០០០** |

**មុខគណនី៖...ចំណាយប្រជុំ** គិតត្រឹមថ្ងៃទី....៣១....ខែ.កក្កដា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មិថុនា | ៣០ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | | | 0 |
| កក្កដា | ២៩ | (ចំណាយប្រជុំប្រចាំខែកក្កដា) | ៣៨,០០០ | | |
| | | **សរុប** | **៣៨,០០០** | 0 | **៣៨,០០០** |

**មុខគណនី៖...សាច់ប្រាក់.........** គិតត្រឹមថ្ងៃទី....៣១....ខែ.កក្កដា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មិថុនា | ៣០ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | | | **៤,៩៦០,០០០** |
| កក្កដា | ០៤ | (បញ្ចូលសមាជិកថ្មីក្នុងសហគមន៍) | ៩២០,០០០ | | |
| កក្កដា | ០៧ | (មីងរី ខ្ចីប្រាក់) | | ២,០០០,០០០ | |
| កក្កដា | ១៣ | (ទទួលបានការប្រាក់ពីពូ សុខ នី) | ៦៤,០០០ | | |
| កក្កដា | ១៥ | (ពូសាក់ ខ្ចីប្រាក់) | | ២,៥០០,០០០ | |
| កក្កដា | ២១ | (ដកប្រាក់ពីធនាគារ) | ១០,០០០,០០០ | | |
| កក្កដា | ២២ | (សាងសង់ទីស្នាក់ការសហគមន៍) | | ៨,៤០០,០០០ | |
| កក្កដា | ២៧ | (សមាជិក បានដាក់ប្រាក់សន្សំ) | ៦០០,០០០ | | |
| កក្កដា | ២៩ | (ចំណាយប្រជុំខែកក្កដា (រដ្ឋបាល)) | | ៣៨,០០០ | |
| | | សរុប | **១១,៥៨៤,០០០** | **១២,៩៣៨,០០០** | **៣,៦០៦,០០០** |

## ជំហានទី៣៖ ធ្វើតារាងតុល្យភាពសាកល្បងចុងគ្រា

| | | | |
|---|---|---|---|
| **១. ទ្រព្យសកម្ម** | សមតុល្យ | **២. បំណុល** | សមតុល្យ |
| **ទ្រព្យសកម្មចល័ត (១)** | | - ប្រាក់ខ្ចីធនាគារ | 18,333,000 |
| - សាច់ប្រាក់ | 3,606,000 | - ប្រាក់សន្សំសមាជិក | 600,000 |
| - ប្រាក់ផ្ញើធនាគារ | 4,033,000 | | |
| - ប្រាក់ឲ្យគេខ្ចី | 9,000,000 | **៣. ទុន** | |
| **ទ្រព្យសកម្មអចល័ត (២)** | | - ប្រាក់ភាគហ៊ុន | 5,800,000 |
| - ដី | 20,000,000 | - ប្រាក់សមាជិកភាព | 620,000 |
| - អគារ | 8,400,000 | - អំណោយរដ្ឋ(ដី) | 20,000,000 |
| **៤. ចំណាយ** | | **៥. ចំណូល** | |
| - ចំណាយរដ្ឋបាល | 38,000 | - ចំណូលការប្រាក់ | 64,000 |
| - ចំណាយការប្រាក់ | 300,000 | - ខាតខែមិថុនា | (-) 40,000 |
| **សរុប** | **45,377,000** | **សរុប** | **45,377,000** |

ឬ

តារាងតុល្យភាពសាកល្បងក្នុងលំហាត់ទី ៣

ត្រឹមថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧

| ឈ្មោះគណនី | ឥណពន្ធ | ឥណទាន |
|---|---|---|
| ១. ទ្រព្យសកម្ម | | |
| - សាច់ប្រាក់ | 3,606,000 | |
| - ប្រាក់ផ្ញើធនាគារ | 4,033,000 | |
| - ប្រាក់ឲ្យគេខ្ចី | 9,000,000 | |
| - ដី | 20,000,000 | |
| - ទីស្នាក់ការ | 8,400,000 | |
| ២. បំណុល | | |
| - ប្រាក់ខ្ចីធនាគារ | | 18,333,000 |
| - ប្រាក់សន្សំសមាជិក | | 600,000 |
| ៣. ទុន | | |
| - ប្រាក់សមាជិកភាព | | 620,000 |
| - ប្រាក់ភាគហ៊ុន | | 5,800,000 |
| - អំណោយរដ្ឋ | | 20,000,000 |
| ៤. ចំណូល | | |
| - ចំណូលការប្រាក់ | | 64,000 |
| - ខាតខែមិថុនា | | (-) 40,000 |
| ៥. ចំណាយ | | |
| - ចំណាយប្រជុំ | 38,000 | |
| - ចំណាយការប្រាក់ | 300,000 | |
| សរុប | 45,377,000 | 45,377,000 |

## ជំហានទី៤៖ ត្រួតពិនិត្យ និងធ្វើតារាងតុល្យភាពកែតម្រូវ

ជំហាននេះ គឺត្រូវរកមើលប្រតិបត្តិការណាដែលមិនទាន់បានចុះបញ្ជីដើម្បីធ្វើការចុះបញ្ជីក្នុងសក្ខីបត្រ និងធ្វើការកែតម្រូវក្នុងតារាងតុល្យភាពកែតម្រូវបន្ត ។

ក្នុងខែកក្កដានេះ មានប្រតិបត្តិការមួយចំនួនដែលយើងមិនបានចុះបញ្ជីគឺ៖

1. ពូសៅ សុខា មិនទាន់បានបង់ការប្រាក់ ចំនួន ២៦,០០០រៀល
2. ការប្រាក់ទទួលបាននៃប្រាក់ផ្ញើធនាគារ គឺត្រូវពិនិត្យមើលលើសៀវភៅធនាគារ ។ ដោយសារមានការលំបាកក្នុងការគិតគូរ ដូច្នេះត្រង់ចំណុចការប្រាក់ផ្ញើធនាគារនេះ យើងសន្មត់ថាមិនទទួលបានទេ ។

**ពេលពិនិត្យឃើញថាមានចំណុចនៅសេសសល់ក្នុងការចុះបញ្ជី អ្នកចុះបញ្ជីត្រូវធ្វើការចុះចូលម្តងទៀតចាប់ពីជំហានទី២ គឺ ៖**

ទិន្នានុប្បវត្តិទូទៅ

| កាលបរិច្ឆេទ | | ឈ្មោះគណនី និងបរិយាយ | ឥណពន្ធ | ឥណទាន |
|---|---|---|---|---|
| ខែ | ថ្ងៃទី | | | |
| កក្កដា | ២៩ | ចំណាយប្រជុំ<br>សាច់ប្រាក់<br>(ចំណាយប្រជុំប្រចាំខែកក្កដា) | ៣៨,០០០ | ៣៨,០០០ |
| កក្កដា | ៣១ | ការប្រាក់ត្រូវទារ<br>ចំណូលការប្រាក់<br>(ពូសៅ សុខា មិនបានបង់ការប្រាក់ពីថ្ងៃទី ១១) | ២៦,០០០ | ២៦,០០០ |

ចំណុចដែលបានធ្វើការកែតម្រូវបន្ថែម

**សំគាល់៖** ករណីដែលមានចំណុចកែតម្រូវតែមួយ ឬមួយចំនួនដែលមានមុខគណនីខុសៗគ្នា គេអាចរំលងសៀវភៅធំ រួចបន្តចូលក្នុងជំហាន ៤ ដោយធ្វើតារាងតុល្យភាពកែតម្រូវតែម្តង ។ ការស្រង់ចេញពីទិន្នានុប្បវត្តិទូទៅចូលទៅក្នុងសៀវភៅធំ គឺក្នុងករណីមានមុខគណនីដូចគ្នាច្រើនៗដែលត្រូវធ្វើការបូកបន្ត ដើម្បីជៀសវាងការភ្លេច ឬបូកច្រឡំ ។

# សៀវភៅធំ ឬ មុខគណនី

**មុខគណនី៖...ចំណូលការប្រាក់** គិតត្រឹមថ្ងៃទី....៣១....ខែ.កក្កដា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មិថុនា | ៣០ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | | | 0 |
| កក្កដា | ១៣ | (ទទួលបានការប្រាក់ពីពូ សុខនី) | | ៦៤,០០០ | |
| | | **សរុប** | 0 | **៦៤,០០០** | **៦៤,០០០** |
| កក្កដា | ៣១ | (ពូសៅ សុខា មិនបានបង់ការប្រាក់ពីថ្ងៃទី ១១) | | ២៦,០០០ | |
| | | សរុប | | ៩០,០០០ | **៩០,០០០** |

ចំណុចដែលបានធ្វើការកែតម្រូវបន្ថែម

**មុខគណនី៖... ការប្រាក់ត្រូវទារ** គិតត្រឹមថ្ងៃទី....៣១....ខែ.កក្កដា...ឆ្នាំ២០១៧.

| កាលបរិច្ឆេទ | | យោងទិន្នានុប្បវត្តិទូទៅ | ឥណពន្ធ | ឥណទាន | សមតុល្យ (សល់ក្នុងខែនេះ) |
|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | |
| មិថុនា | ៣០ | **យោងសមតុល្យដើមគ្រា(សល់ពីខែមុន)** | | | 0 |
| កក្កដា | ៣១ | (ពូសៅ សុខា មិនបានបង់ការប្រាក់ពីថ្ងៃទី ១១) | ២៦,០០០ | | |
| | | **សរុប** | **២៦,០០០** | 0 | **២៦,០០០** |

# តារាងតុល្យភាពកែតម្រូវ

| ឈ្មោះគណនី | តារាងតុល្យភាពសមតុល្យ | | ទិន្នានុប្បវត្តិកែតម្រូវ ដើម្បីបិទបញ្ជី | | សមតុល្យក្រោយកែតម្រូវ | |
|---|---|---|---|---|---|---|
| | ឥណពន្ធ | ឥណទាន | ឥណពន្ធ | ឥណទាន | ឥណពន្ធ | ឥណទាន |
| សាច់ប្រាក់ | 3,606,000 | | | | 3,606,000 | |
| ប្រាក់ផ្ញើធនាគារ | 4,033,000 | | | | 4,033,000 | |
| ប្រាក់ឲ្យគេខ្ចី | 9,000,000 | | | | 9,000,000 | |
| *ការប្រាក់ត្រូវទារ* | | | *26,000* | | *26,000* | |
| ដី | 20,000,000 | | | | 20,000,000 | |
| អគារ | 8,400,000 | | | | 8,400,000 | |
| ប្រាក់ខ្ចីធនាគារ | | 18,333,000 | | | | 18,333,000 |
| ប្រាក់បញ្ញើសន្សំ | | 600,000 | | | | 600,000 |
| ប្រាក់សមាជិក | | 620,000 | | | | 620,000 |
| ប្រាក់ភាគហ៊ុន | | 5,800,000 | | | | 5,800,000 |
| អំណោយរដ្ឋ | | 20,000,000 | | | | 20,000,000 |
| ខាតខែមិថុនា | | ( ) 40,000 | | | | ( ) 40,000 |
| *ចំណូលការប្រាក់* | | 64,000 | | *26,000* | | *90,000* |
| ចំណាយប្រជុំ | 38,000 | | | | 38,000 | |
| ចំណាយការប្រាក់ | 300,000 | | | | 300,000 | |
| **សរុប** | **45,377,000** | **45,377,000** | **26,000** | **26,000** | **45,403,000** | **45,403,000** |

# ជំហានទី៥៖ តារាងរបាយការណ៍ហិរញ្ញវត្ថុ

## តារាងតុល្យការ

## ត្រឹមថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧

## (គិតជារៀល)

| ១. ទ្រព្យសកម្ម | សមតុល្យ | ២. បំណុល | សមតុល្យ |
|---|---|---|---|
| ទ្រព្យសកម្មចលត៍ (១) | | - ប្រាក់ខ្ចីធនាគារ | 18,333,000 |
| - សាច់ប្រាក់ | 3,606,000 | - ប្រាក់បញ្ញើសន្សំ | 600,000 |
| - ប្រាក់ផ្ញើធនាគារ | 4,033,000 | | |
| - ប្រាក់ឲ្យគេខ្ចី | 9,000,000 | ៣. ទុន | |
| - ការប្រាក់ត្រូវទារ | 26,000 | - ប្រាក់ភាគហ៊ុន | 620,000 |
| ទ្រព្យសកម្មអចលត៍ (២) | | - ប្រាក់សមាជិកភាព | 5,800,000 |
| - ដី | 20,000,000 | - អំណោយរដ្ឋ(ដី) | 20,000,000 |
| - អគារ | 8,400,000 | - ខាត | (-) 288,000 |
| សរុប (១)+(២) | 45,065,000 | សរុប ២+៣ | 45,065,000 |

## របាយការណ៍លទ្ធផល

៣១ កក្កដា ២០១៧

| | | |
|---|---|---|
| **ខាត/ចំណេញខែមិថុនា** | | () 40,000 |
| **ចំណូលខែកក្កដា** | | |
| ចំណូលការប្រាក់ខែ | | 90,000 |
| សរុបចំណូល | | 90,000 |
| **ចំណាយខែកក្កដា** | | |
| ចំណាយប្រជុំប្រចាំខែកក្កដា | 38,000 | |
| ចំណាយការប្រាក់ | 3000,00 | |
| សរុបចំណាយ | 338,000 | |
| **ខាត/ចំណេញសុទ្ធ** | | ( ) 288,000 |

# គំរូនៃការវិភាគប្រតិបត្តិ

ខាងក្រោមគឺជាគំរូឈ្មោះគណនីមួយចំនួនរបស់ប្រតិបត្តិការ ដែលបានកំណត់គណនីខាងឥណពន្ធ និងឥណទាន៖

I- **ប័ណ្ណចំណូលជាសាច់ប្រាក់នៅក្នុងបេឡា (កត់ត្រាក្នុងប័ណ្ណចំណូល)**

*ខ្ចីប្រាក់ពីធនាគារ*

ឥណពន្ធ គណនីសាច់ប្រាក់............. ឥណទាន គណនីប្រាក់ខ្ចីធនាគារ............

*ចំណូលពីការប្រាក់*

ឥណពន្ធ គណនីសាច់ប្រាក់............. ឥណទាន គណនីការប្រាក់....................

*ចំណូលពីការលក់ទំនិញ*

ឥណពន្ធ គណនីសាច់ប្រាក់............ ឥណទាន គណនីលក់ទំនិញ.................

*ចំណូលពីសេវាផ្សេងៗ*

ឥណពន្ធ គណនីសាច់ប្រាក់........... ឥណទាន គណនីសេវាជួល....................

*ចំណូលអតិថិជនសងប្រាក់*

ឥណពន្ធ គណនីសាច់ប្រាក់........... ឥណទាន គណនីអតិថិជន...................

*ចំណូលពេលបង់ភាគហ៊ុន*

ឥណពន្ធ គណនីសាច់ប្រាក់........... ឥណទាន គណនីភាគហ៊ុន.................

*ចំណូលពីអំណោយរដ្ឋាភិបាល ឬ សប្បុរសជន*

ឥណពន្ធ គណនីសាច់ប្រាក់.......... ឥណទាន គណនីអំណោយរដ្ឋាភិបាល ឬ សប្បុរសជន...............................

*ពេលបើកប្រាក់ពីធនាគារ*

ឥណពន្ធ គណនីសាច់ប្រាក់.......... ឥណទាន គណនីប្រាក់ផ្ញើធនាគារ.........

*ពេលសមាជិកសងប្រាក់ដើមមកវិញ*

ឥណពន្ធ គណនីសាច់ប្រាក់......... ឥណទាន គណនីឲ្យខ្ចីប្រាក់............

*ពេលសមាជិកសងការប្រាក់*

ឥណពន្ធ គណនីសាច់ប្រាក់......... ឥណទាន គណនីចំណូលការប្រាក់........

## II- ប័ណ្ណចំណាយជាសាច់ប្រាក់នៅក្នុងបេឡា (ធ្វើប័ណ្ណចំណាយ)

*ចំណាយទិញទំនិញ*

ឥណពន្ធ គណនីទិញទំនិញ......... ឥណទាន គណនីសាច់ប្រាក់.........

*ចំណាយសងថ្លៃទំនិញទិញជឿ*

ឥណពន្ធ គណនីអ្នកផ្គត់ផ្គង់......... ឥណទាន គណនីសាច់ប្រាក់.........

*ចំណាយទិញប្រេងឥន្ធនៈ*

ឥណពន្ធ គណនីប្រេងឥន្ធនៈ......... ឥណទាន គណនីសាច់ប្រាក់.........

*ចំណាយទិញសម្ភារៈការិយាល័យ*

ឥណពន្ធ គណនីសម្ភារៈការិយាល័យ... ឥណទាន គណនីសាច់ប្រាក់.........

*ចំណាយទិញឧបករណ៍ការិយាល័យ*

ឥណពន្ធ គណនីឧបករណ៍ការិយាល័យ... ឥណទាន គណនីសាច់ប្រាក់.........

*ចំណាយទិញម៉ាស៊ីនបូមទឹក*

ឥណពន្ធ គណនីម៉ាស៊ីនបូមទឹក......... ឥណទាន គណនីសាច់ប្រាក់.........

*ចំណាយចុះបេសកកម្ម*

ឥណពន្ធ គណនីចំណាយបេសកកម្ម... ឥណទាន គណនីសាច់ប្រាក់.........

*ចំណាយសងការប្រាក់ដែលបានខ្ចីពីធនាគារ*

ឥណពន្ធ គណនីការប្រាក់ .............. ឥណទាន គណនីសាច់ប្រាក់.........

*ពេលឲ្យសមាជិកខ្ចីប្រាក់ (មានលិខិតធានា)*

ឥណពន្ធ គណនីប្រាក់ឲ្យខ្ចី ............ ឥណទាន គណនីសាច់ប្រាក់.........

*ពេលសមាជិកសងប្រាក់ដើមមកវិញ*

ឥណពន្ធ គណនីសាច់ប្រាក់ .......... ឥណទាន គណនីប្រាក់ឲ្យខ្ចី.........

*ពេលសមាជិកសងការប្រាក់*

ឥណពន្ធ គណនីសាច់ប្រាក់ ......... ឥណទាន គណនីចំណូលការប្រាក់.....

## III- ការចុះទិនានុប្បវត្តិប្រាក់ផ្ញើធនាគារ

*ពេលសុំបើកគណនីធនាគារ*

ឥណពន្ធ គណនីប្រាក់ផ្ញើធនាគារ......... ឥណទាន គណនីសាច់ប្រាក់............

*ពេលយកប្រាក់ទៅផ្ញើធនាគារ*

ឥណពន្ធ គណនីប្រាក់ផ្ញើធនាគារ......... ឥណទាន គណនីសាច់ប្រាក់..............

*ពេលធនាគារយកថ្លៃសេវា (កាត់ពីក្នុងគណនី) ត្រូវថតភ្ជាប់សន្លឹកដែលមានកាត់ទឹកប្រាក់*

ឥណពន្ធ គណនីសេវាធនាគារ......... ឥណទាន គណនីប្រាក់ផ្ញើធនាគារ......

*ពេលធនាគារយកថ្លៃសេវា (បង់សាច់ប្រាក់ក្រៅ)*

ឥណពន្ធ គណនីសេវាធនាគារ......... ឥណទាន គណនីសាច់ប្រាក់.............

*ពេលទទួលបានការប្រាក់ពីធនាគារ*

ឥណពន្ធ គណនីប្រាក់ផ្ញើធនាគារ......... ឥណទាន គណនីចំណូលការប្រាក់......

## IV- ការចុះទិនានុប្បវត្តិអាជីវកម្មជំនឿទុកចិត្ត (មុខរបរឥណទាន)

គឺជាសកម្មភាពរបស់សហគមន៍ក្នុងនាមជាស្ថាប័នហិរញ្ញវត្ថុ ដោយចលនាឲ្យប្រជាជនជាសមាជិក យកប្រាក់មកផ្ញើ និងឲ្យប្រាក់ទៅសមាជិកខ្ចីវិញ ។

☞ ***<u>ការចុះទិនានុប្បវត្តិលើអាជីវកម្មជំនឿទុកចិត្ត</u>***

*<u>ពេលទទួលប្រាក់បញ្ញើសន្សំ</u>*

ឥណពន្ធ គណនីសាច់ប្រាក់......... ឥណទានគណនីប្រាក់បញ្ញើសន្សំ....

*<u>ពេលទទួលប្រាក់បញ្ញើមានកាលកំណត់</u>*

ឥណពន្ធ គណនីសាច់ប្រាក់......... ឥណទានគណនីប្រាក់បញ្ញើមានកាល កំណត់...

*<u>ពេលឲ្យការប្រាក់ទៅសមាជិក</u>*

ឥណពន្ធ គណនីចំណាយការប្រាក់......... ឥណទាន គណនីសាច់ប្រាក់.........

*<u>ពេលឲ្យសមាជិកខ្ចីប្រាក់</u>* ( *<u>មានលិខិតធានា</u>*)

ឥណពន្ធ គណនីប្រាក់ឲ្យខ្ចី .......... ឥណទាន គណនីសាច់ប្រាក់.........

## V- ការចុះទិនានុប្បវត្តិអាជីវកម្មផ្គត់ផ្គង់

គណនីដែលត្រូវប្រើញឹកញាប់ក្នុងមុខរបរផ្គត់ផ្គង់៖ គឺមុខរបរទិញ-លក់ដី លក់ចំណីសត្វ

- គណនីអតិថិជន ឬ គណនីត្រូវទារ៖ ពេលលក់ទំនិញជឿ
- គណនីអ្នកផ្គត់ផ្គង់ ឬ គណនីត្រូវសង៖ ពេលទិញទំនិញជឿ
- គណនីស្តុកទំនិញ៖ ពេលធ្វើសារពើភ័ណ្ឌ (ចុះបញ្ជីទ្រព្យសម្បត្តិដែលមានក្នុងសហគមន៍ទាំងទ្រព្យនិងទំនិញ)
- គណនីទិញទំនិញ៖ ពេលទិញទំនិញចូល
- គណនីបុរេប្រទានបង់មុន៖ ពេលទិញទំនិញកក់ប្រាក់
- គណនីបុរេប្រទានទទួលមុន៖ ពេលលក់ទំនិញទទួលបានប្រាក់កក់

**ការចុះទិនានុប្បវត្តិអាជីវកម្មផ្គត់ផ្គង់៖**

*<u>ពេលទិញទំនិញជាសាច់ប្រាក់</u>*

ឥណពន្ធ គណនីទិញទំនិញ......... ឥណទាន គណនីសាច់ប្រាក់.........

*<u>ពេលទិញទំនិញជឿ</u>*

ឥណពន្ធ គណនីទិញទំនិញ......... ឥណទាន គណនីអ្នកផ្គត់ផ្គង់.........

*<u>ពេលទិញទំនិញឲ្យប្រាក់ខ្លះ</u>* *<u>ជំពាក់ខ្លះ</u>*

ឥណពន្ធ គណនីទិញទំនិញ......... ឥណទាន គណនីសាច់ប្រាក់.........

ឥណទាន គណនីអ្នកផ្គត់ផ្គង់.........

*__ពេលទិញទំនិញកក់ប្រាក់__*

ឥណពន្ធ គណនីបុរេប្រទានបង់មុន......... ឥណទាន គណនីសាច់ប្រាក់.........

*__ពេលលក់ទំនិញជឿ__*

ឥណពន្ធ គណនីអតិថិជន......... ឥណទាន គណនីចំណូលពីការលក់....

*__ពេលលក់ទំនិញជាសាច់ប្រាក់__*

ឥណពន្ធ គណនីសាច់ប្រាក់......... ឥណទាន គណនីលក់ទំនិញ.........

*__ពេលលក់ទំនិញឲ្យប្រាក់ខ្លះ ជំពាក់ខ្លះ__*

ឥណពន្ធ គណនីសាច់ប្រាក់........... ឥណពន្ធ គណនីអតិថិជន................

ឥណទាន គណនីលក់ទំនិញ.........

*__ពេលលក់ទំនិញទទួលបានប្រាក់កក់__*

ឥណពន្ធ គណនីសាច់ប្រាក់......... ឥណទាន គណនីបុរេប្រទានបានទទួលមុន

*__ពេលធ្វើសារពើភ័ណ្ឌ មានទំនិញសល់ លក់មិនអស់__*

ឥណពន្ធ គណនីស្តុកទំនិញ......... ឥណទាន គណនីទិញទំនិញ.........

# បញ្ជីឈ្មោះគណនីក្នុងផ្នែកទាំង ៥

| ផ្នែក | ឈ្មោះគណនី | ការពន្យល់អំពីខ្លឹមសារ |
| --- | --- | --- |
| ទ្រព្យសកម្ម | សាច់ប្រាក់ ឬ បេឡា<br>គណនីប្រាក់ផ្ញើធនាគារ<br>ប្រាក់ឲ្យខ្ចីមានលិខិតសន្យា<br>គណនីអតិថិជន ឬ គណនីត្រូវទារ<br>ដីធ្លី<br>អគារ<br>ឧបករណ៍ការិយាល័យ<br>សម្ភារៈដឹកជញ្ជូន<br>សម្ភារៈផ្សេងៗ | ប្រាក់ដែលមាននៅក្នុងដៃ (រូបិយប័ណ្ណ ជាដើម)<br>គណនីដែលផ្ញើនៅតាមស្ថាប័នហិរញ្ញវត្ថុដូចជាធនាគារជាដើម<br>ប្រាក់ឲ្យសមាជិកខ្ចី<br>ថ្លៃលក់ទំនិញផ្គត់ផ្គង់ តែមិនទាន់បានទទួលប្រាក់ (លក់ទំនិញជឿជូនអតិថិជន)<br>ដីដែលជាកម្មសិទ្ធិរបស់សហគមន៍កសិកម្ម<br>អគារដែលជាកម្មសិទ្ធិរបស់សហគមន៍កសិកម្ម<br>តុ និងកុំព្យូទ័រជាដើមដែលជាកម្មសិទ្ធិរបស់សហគមន៍កសិកម្ម<br>សម្ភារៈដឹកជញ្ជូនដែលជាកម្មសិទ្ធិរបស់សហគមន៍កសិកម្ម |
| បំណុល | ប្រាក់បញ្ញើមានកាលកំណត់ ឬ បញ្ញើសន្សំ<br>ប្រាក់ខ្ចីពីធនាគារ<br>គណនីអ្នកផ្គត់ផ្គង់ ឬ គណនីត្រូវសងប្រាក់មិនទាន់បង់ | ប្រាក់បញ្ញើរបស់សមាជិកជាដើម (បញ្ញើក្រៅពីសមាជិកក៏មានដែរ)<br>ប្រាក់ដែលខ្ចីមកពីធនាគារ<br>ថ្លៃទិញទំនិញផ្គត់ផ្គង់ តែមិនទាន់បានបង់ (ទិញទំនិញជឿ)<br>គណនីអ្នកផ្គត់ផ្គង់ បំណុលក្រៅពីថ្លៃទិញជឿនូវទំនិញសម្រាប់លក់ |
| ទុន<br>សហគមន៍ | ប្រាក់ចូលហ៊ុន<br>ប្រាក់សមាជិកតាព<br>មូលនិធិបំរុង<br>ទុនបណ្តុះបណ្តាល<br>អតិរេកមិនទាន់ចាត់ចែង<br>អំណោយពីសប្បុរសជន និងអង្គការ<br>អំណោយពីរាជរដ្ឋាភិបាល | បរិមាណទឹកប្រាក់ដែលសមាជិកដាក់ទុនវិនិយោគ<br>ប្រាក់បង់ចូលជាពីសមាជិក<br>ប្រាក់ដែលត្រូវដកពីប្រាក់ចំណេញសុទ្ធសម្រាប់បំរុងទុក ២០% ប្រចាំឆ្នាំ<br>ប្រាក់ដែលត្រូវដកពីប្រាក់ចំណេញសុទ្ធសម្រាប់បំរុងទុក ០៣% ប្រចាំឆ្នាំ<br>ប្រាក់ចំណេញសុទ្ធបានពីមុខរបរសហគមន៍<br>ប្រាក់អំណោយពីសប្បុរសជន និងអង្គការនានា<br>ប្រាក់អំណោយពីរដ្ឋ |
| ចំណាយ | ការប្រាក់នៃប្រាក់បញ្ញើ<br>ការប្រាក់កម្ចី<br>ចំណាយទិញទំនិញ<br>ចំណាយលើការធ្វើដំណើរ<br>ចំណាយលើទូរគមនាគមន៍<br>ចំណាយលើកដាក់លើសែង<br>ចំណាយផ្សេងៗ | ការប្រាក់នៃប្រាក់បញ្ញើ<br>ការប្រាក់នៃប្រាក់កម្ចី<br>ថ្លៃទិញទំនិញសម្រាប់ផ្គត់ផ្គង់<br>ថ្លៃធ្វើដំណើរទៅធ្វើការខាងក្រៅ និងថ្លៃធ្វើដំណើរទៅធ្វើការនៅការិយាល័យ<br>ថ្លៃទំនាក់ទំនងដូចជាប្រៃសណីយ៍ និងទូរសព្ទជាដើម<br>ថ្លៃចំណាយលើកម្មករ<br>ថ្លៃចំណាយផ្សេងទៀត |
| ចំណូល | ការប្រាក់នៃប្រាក់ផ្ញើធនាគារ<br>ការប្រាក់នៃប្រាក់ឲ្យគេខ្ចី<br>ចំណូលពីការលក់ទំនិញ<br>កម្រៃជើងសារទទួលបាន<br>ចំណូលពីសេវាកម្មផ្សេងៗ | បរិមាណការប្រាក់បានមកពីប្រាក់ផ្ញើនៅធនាគារ<br>បរិមាណការប្រាក់បានមកពីប្រាក់ដែលឲ្យគេខ្ចី<br>ថ្លៃលក់ទំនិញផ្គត់ផ្គង់<br>បរិមាណកម្រៃជើងសារដែលទទួលបានដោយការផ្តល់សេវាកម្ម |

# វិធីសាស្ត្រកត់ត្រាគណនីទាំង៥ ឬ
# វិធានកត់ត្រា ឥណពន្ធ និងឥណទាន

ចំពោះផ្នែកគណនីទាំង ៥ រួមមាន គណនីទ្រព្យសកម្ម គណនីបំណុល គណនីទុនសមាជិក គណនីចំណាយ និងគណនីចំណូល គឺត្រូវគោរពតាមគោលការណ៍នៃការកត់ត្រាឥណពន្ធ និងឥណទាន ដូចខាងក្រោម៖

**ទ្រព្យសកម្ម**

| កើនឡើង | ថយចុះ |
|---|---|

**បំណុល**

| ថយចុះ | កើនឡើង |
|---|---|

**ទុន**

| ថយចុះ | កើនឡើង |
|---|---|

**ចំណាយ**

| កើតមាន | លុបចោល |
|---|---|

**ចំណូល**

| លុបចោល | កើតមាន |
|---|---|

# ឯកសារយោង

1. ឯកឧត្តម ម៉ម អំណាត់ និង លោកស្រី វង្ស ផល្លា, ២០១៧, ឯកសារបណ្តុះបណ្តាលស្តីពីការចុះបញ្ជីគណនេយ្យសម្រាប់សហគមន៍កសិកម្ម, នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម
2. ឯកសារបណ្តុះបណ្តាលស្តីពី គណនេយ្យ និងការគ្រប់គ្រងបញ្ជីគណនេយ្យសម្រាប់សហគមន៍កសិកម្ម, នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម, ២០១៤
3. ឯកសារបណ្តុះបណ្តាលស្តីពី បញ្ជីគណនេយ្យថ្មីរបស់សហគមន៍កសិកម្មកម្ពុជា, នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម, ២០១០